**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics


## សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន នៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


| | |
|---|---|
| ស្រាវជ្រាវដោយ | ណែនាំដោយ |
| និស្សិតឈ្មោះ **កញ្ញា ឆន់ ស្រីពៅ** | សាស្ត្រាចារ្យជំនួយ **បណ្ឌិត អ៊ុន សភក្កដា** |
| **លោក តោក វ៉ាឃីម** | |


| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | | ឆ្នាំចូលរៀន | ២០២០ |
| ជំនាន់ទី២៩ (អាហារូបករណ៍) | | ឆ្នាំសរសេរសារណា | ២០២៤ |

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន នៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

| | |
|---|---|
| ស្រាវជ្រាវដោយ | ណែនាំដោយ |
| និស្សិតឈ្មោះ **កញ្ញា ធន់ ស្រីពៅ** | សាស្ត្រាចារ្យជំនួយ **បណ្ឌិត អ៊ុន សកក្កដា** |
| **លោក តោក វ៉ាឃីម** | |
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលរៀន ២០២០ |
| ជំនាន់ទី២៩ (អាហារូបករណ៍) | ឆ្នាំសរសេរសារណា ២០២៤ |

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ឆន់ ស្រីពៅ** និងខ្ញុំបាទឈ្មោះ **តោក ទ៉ាឃីម** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២៩ ឆ្នាំសិក្សា២០២០-២០២៤។

ជាបឋមខ្ញុំបាទ និងនាងខ្ញុំសូមលំឱនកាយវាចាចិត្តដើម្បីសម្តែងការគោរព ការដឹងគុណ និងកតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះអ្នកមានគុណទាំងទ្វេ គឺៈ

- **លោកឪពុក ឃុន សុភី និងអ្នកម្តាយ ប៉ុល រ៉ាន្នី**
- **លោកឪពុក ស៊ឹម បេ និងអ្នកម្តាយ ម៉ក់ អូន**

ដែលលោកបានផ្តល់កំណើត ខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីនៅក្នុងផ្ទៃរហូតដល់ធំធាត់ពេញវ័យ ដោយក្តីស្រឡាញ់ ការពារ និងមើលថែទាំកូនយ៉ាងយកចិត្តទុកដាក់បំផុត។ មិនតែប៉ុណ្ណោះលោកពុក អ្នកម៉ែតែង តែអប់រំប្រៀនប្រដៅកូនឱ្យធ្វើជាមនុស្សល្អ ឱ្យខិតខំតស៊ូរៀនសូត្រដើម្បីក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អ ព្រមទាំងផ្តល់ឱកាសឱ្យកូនបានរៀនសូត្រតាំងពីថ្នាក់មត្តេយ្យសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សានេះ ដើម្បីឱ្យកូន មានចំណេះវិជ្ជាជាទ្រព្យជាប់នឹងប្រាណសម្រាប់ជាប្រយោជន៍ក្នុងការរស់នៅ និងមានអនាគតមួយដ៏ល្អប្រសើរ។ លោកពុក អ្នកម៉ែមានគុណដ៏ធំធេងថ្លៃថ្លាណាស់ចំពោះកូនដែលពុំអាចមានអ្វីវាស់ និងកាត់ថ្លៃបានឡើយ កូននឹង ចងចាំព្រះគុណរបស់លោកពុក អ្នកម៉ែជាប់ក្នុងចិត្តរបស់កូនជានិច្ចពុំមានថ្ងៃបំភ្លេចឡើយ។

ខ្ញុំបាទ និងនាងខ្ញុំ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យ** ទាំងអស់នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំ បង្ហាត់បង្រៀនផ្តល់ចំណេះដឹងដល់ខ្ញុំបាទ និងនាងខ្ញុំក្នុងរយៈពេល៤ឆ្នាំនេះ។ ជាពិសេសសូមថ្លែងអំណរគុណ យ៉ាងជ្រាវជ្រៅចំពោះ **លោកសាស្ត្រាចារ្យជំនួយបណ្ឌិត អ៊ុន សកក្កដា** ដែលជាសាស្ត្រាចារ្យទទួល បន្ទុកណែនាំសារណា លោកបានលះបង់នូវពេលវេលាដ៏មានតម្លៃព្រមទាំងកម្លាំងកាយចិត្ត ពន្យល់ណែនាំចង្អុល បង្ហាញនៅក្នុងដំណើរការនៃការតាក់តែងកិច្ចការស្រាវជ្រាវមួយនេះរហូតបានសម្រេចប្រកបដោយភាពជោគជ័យ។

ជាចុងក្រោយខ្ញុំបាទ និងនាងខ្ញុំសូមគោរពជូនពរ និងសូមបួងសួងដល់ទេវតា វត្ថុស័ក្តសិទ្ធិទាំងឡាយ ក្នុងលោក សូមជួយថែរក្សាដល់លោកអ្នកមានគុណទាំងអស់ដែលបានរៀបរាប់ខាងលើសូមជួបតែពុទ្ធពរទាំងបួន ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ និងសូមបួងសួងឱ្យប្រទេសកម្ពុជាយើង ព្រមទាំង ប្រជាជនខ្មែរទាំងអស់ជួបតែសេចក្តីសុខសន្តិភាព សុវត្ថិភាព ភាពរុងរឿងរីកចម្រើនទៅមុខតរៀងទៅ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេលបួនឆ្នាំមកដែលសិក្សាទៅលើមុខវិជ្ជាជាច្រើន សិក្សាពីវិស័យច្បាប់នៅកម្ពុជាដែលទាក់ទងទាំងវិស័យសាធារណៈ និងវិស័យឯកជនដែលមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ឱ្យប្រជាពលរដ្ឋកម្ពុជាយើងគ្រប់រូបត្រូវរៀនសូត្រ ត្រូវដឹង ត្រូវស្វែងយល់ពីវិស័យច្បាប់នៅកម្ពុជាយើង។ ដោយមានការជ្រោមជ្រែង និងយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់របស់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យនានា ទើបធ្វើឱ្យខ្ញុំបាទ និងនាងខ្ញុំអាចឈានមកដល់ការចងក្រងសារណា ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រជំនាន់ទី២៩ (អាហារូបករណ៍) និងដើម្បីចូលរួមចែករំលែកចំណេះដឹងដល់និស្សិតជំនាន់ក្រោយៗផង។ ខ្ញុំបាទ និងនាងខ្ញុំបានសម្រេចចិត្តស្រាវជ្រាវចងក្រងសារណាអំពីប្រធានបទ « **នីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាននៅកម្ពុជា** » ពីព្រោះខ្ញុំបាទ និងនាងខ្ញុំមើលឃើញអំពីសារៈសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋានដែលជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបត្រូវមានតួនាទីដើម្បីស្នើសុំចុះបញ្ជីអត្រានុកូលដ្ឋាន និងបានមើលឃើញពីបញ្ហាផ្សេងៗក្នុងសង្គមបច្ចុប្បន្នទាក់ទងទៅនឹងការចុះបញ្ជីអត្រានុកូលដ្ឋាននេះ។ ដូច្នេះហើយខ្ញុំបាទ និងនាងខ្ញុំបានខិតខំស្រាវជ្រាវចងក្រងសារណាមួយនេះឡើងដើម្បីឱ្យសាធារណជន សិស្សនិស្សិត និងអ្នកសិក្សាស្រាវជ្រាវទាំងអស់គ្នាបានយល់ដឹងឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតអំពីអត្រានុកូលដ្ឋាន ម៉្យាងទៀតខ្ញុំទាំងពីរនាក់ចង់បន្សល់ទុកនូវស្នាដៃមួយដើម្បីជាការចងចាំដែលខ្ញុំបាទ និងនាងខ្ញុំក៏ធ្លាប់ជាអតីតនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ខ្ញុំបាទ និងនាងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយខ្លាំងណាស់ដែលទទួលបានឱកាសមួយនេះក្នុងការបញ្ចេញសមត្ថភាព ព្រមទាំងចំណេះដឹងដែលទទួលបានតាមរយៈការសិក្សាកន្លងមក ហើយខ្ញុំបាទ និងនាងខ្ញុំសង្ឃឹមថាប្រធានបទសារណាមួយនេះនឹងក្លាយជាពុទ្ធិ និងជាប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវ សិស្សនិស្សិតព្រមទាំងសាធារណជនដើម្បីយកមកធ្វើជាចំណេះដឹងបន្ថែម និងជួយចែករំលែកបន្តទៀតផងដែរ។

ខ្ញុំបាទ និងនាងខ្ញុំក៏សូមធ្វើការខន្តី អភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងទាំងឡាយក្នុងប្រការណាមួយដោយអចេតនា ទោះបីជាខ្ញុំបាទ និងនាងខ្ញុំបានខិតខំប្រឹងប្រែងស្រាវជ្រាវសម្រិតសម្រាំងយ៉ាងណាក្តីក៏សារណាមួយនេះនៅតែមានចំណុចខ្វះខាត ដោយអចេតនានៅត្រង់ចំណុចណាមួយ ដូចជាការប្រើប្រាស់ពាក្យពេចន៍ អក្ខរាវិរុទ្ធ អត្ថន័យ ឬកំហុសឆ្គងដោយអចេតនាណាមួយដែលមាននៅក្នុងសារណាមួយនេះ។ ហេតុដូចនេះខ្ញុំបាទ និងនាងខ្ញុំ សូមធ្វើការអភ័យទោសរាល់កំហុសឆ្គងដែលកើតឡើងដោយអចេតនា និងទទួលយករាល់មតិយោបល់ ការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់សាស្ត្រាចារ្យ រៀមច្បង មិត្តនិស្សិត ទាំងអស់គ្នាដើម្បីឱ្យស្នាដៃមួយនេះមានភាពល្អប្រសើរឡើងបន្ថែមទៀត។

# មាតិកា


ទំព័រ

**ពាក្យគន្លឹះ** ............ iv

**សេចក្តីផ្តើម** ............ 1

**ជំពូកទី១**

**សញ្ញាណទូទៅនៃអត្រានុកូលដ្ឋាន**

**១.១. សាវតានៃអត្រានុកូលដ្ឋាន** ............ 4

១.១.១. នៅមុនឆ្នាំ១៩៩៣ ............ 4

១.១.២. ក្រោយឆ្នាំ១៩៩៣ដល់បច្ចុប្បន្ន ............ 5

**១.២. ប្រភេទនៃអត្រានុកូលដ្ឋាន** ............ 6

១.២.១. អត្រានុកូលដ្ឋានកំណើត ............ 6

១.២.១.១. សំបុត្រកំណើត ............ 6

១.២.១.២. សំបុត្របញ្ជាក់កំណើត ............ 7

១.២.២. អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ............ 8

១.២.២.១. សំបុត្រអាពាហ៍ពិពាហ៍ ............ 8

១.២.២.២. សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ............ 9

១.២.៣. អត្រានុកូលដ្ឋានមរណភាព ............ 9

១.២.៣.១. សំបុត្រមរណភាព ............ 9

១.២.៣.២. សំបុត្របញ្ជាក់មរណភាព ............ 10

**១.៣. សារៈសំខាន់នៃអត្រានុកូលដ្ឋាន** ............ 11

១.៣.១. សារៈសំខាន់នៃអត្រានុកូលដ្ឋានកំណើត ............ 12

១.៣.២. សារៈសំខាន់នៃអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ........ 12
១.៣.៣. សារៈសំខាន់នៃអត្រានុកូលដ្ឋានមរណភាព ........ 13
**១.៤. មន្ត្រីមានសមត្ថកិច្ចនៃអត្រានុកូលដ្ឋាន** ........ 13
១.៤.១. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ........ 13
១. ៤.២. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ........ 14
១.៤.៣. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ........ 15
១.៤.៤. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ........ 16

## ជំពូកទី២

## នីតិវិធីនៃការសុំចុះបញ្ជីអត្រានុកូលដ្ឋានកំណើត អាពាហ៍ពិពាហ៍ និងមរណភាព

**២.១. ការសុំចុះបញ្ជីអត្រានុកូលដ្ឋាន និងសៀវភៅអត្រានុកូលដ្ឋាន** ........ 18
២.១.១. ឯកសារនៃការចុះបញ្ជីអត្រានុកូលដ្ឋាន ........ 18
២.១.១.១. ឯកសារនៃការចុះបញ្ជីអត្រានុកូលដ្ឋានកំណើត ........ 19
២.១.១.២. ឯកសារនៃការចុះបញ្ជីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ........ 22
២.១.១.៣. ឯកសារនៃការចុះបញ្ជីអត្រានុកូលដ្ឋានមរណភាព ........ 23
២.១.២. ការដាក់ពាក្យសុំចុះបញ្ជីអត្រានុកូលដ្ឋាន ........ 26
២.១.២.១. ការដាក់ពាក្យសុំចុះបញ្ជី និងបញ្ជាក់អត្រានុកូលដ្ឋានកំណើត ........ 26
២.១.២.២. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងបញ្ជាក់សំបុត្រអាពាហ៍ពិពាហ៍ ........ 28
២.១.២.៣. ការដាក់ពាក្យចុះបញ្ជី និងបញ្ជាក់អត្រានុកូលដ្ឋានមរណភាព ........ 30
**២.២. សេចក្តីចម្លងអត្រានុកូលដ្ឋាន និងការជូនដំណឹងនៃអត្រានុកូលដ្ឋាន** ........ 31
២.២.១. សេចក្តីចម្លងអត្រានុកូលដ្ឋាន ........ 31
២.២.១.១. សេចក្តីចម្លងអត្រានុកូលដ្ឋានកំណើត និងសម្រង់បញ្ជីកំណើត ........ 31
២.២.១.៣. សេចក្តីចម្លងអត្រានុកូលដ្ឋានមរណភាព និងសម្រង់បញ្ជីមរណភាព ........ 33

២.២.២. ការជូនដំណឹងនៃអត្រានុកូលដ្ឋាន 34

២.២.២.១. ការជូនដំណឹងអំពីកំណើត 34

២.២.២.២. ការជូនដំណឹងនៃអាពាហ៍ពិពាហ៍ 35

២.២.២.៣. ការជូនដំណឹងនៃមរណភាព 37

**២.៣. បញ្ហាប្រឈម និងដំណោះស្រាយ** 39

២.៣.១. បញ្ហាប្រឈមនៃការចុះបញ្ជីអត្រានុកូលដ្ឋាន 39

២.៣.២. ដំណោះស្រាយចំពោះបញ្ហាប្រឈមនៃការចុះបញ្ជីអត្រានុកូលដ្ឋាន 40

**សេចក្ដីសន្និដ្ឋាន** ៤៥

**អនុសាសន៍** 45

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# ពាក្យគន្លឹះ

**ការចងក្រងស្ថិតិអត្រានុកូលដ្ឋាន** សំដៅទៅដល់ដំណើរការនៃការបង្រួម និងការសង្ខេបព័ត៌មានអំពីព្រឹត្តិការណ៍ជីវិតតាមរយៈការចាត់ថ្នាក់ និងរៀបឡើងជាតារាងទិន្នន័យទៅតាមប្រភេទ ឬទៅតាមក្រុមដើម្បីផលិតនូវស្ថិតិអត្រានុកូលដ្ឋានផ្អែកទៅតាមតារាងដែលត្រូវបានកំណត់ទុកជាមុន។

**កំណើតរស់** សំដៅទៅដល់ការធាក់ចេញ ឬការទាញចេញពេញលេញនូវផលិតផលគភ៌ពីម្ដាយដោយមិនគិតរយៈពេលនៃការមានគភ៌ ហើយបន្ទាប់ពីការបំបែកចេញពីម្ដាយនោះ ទារកដកដង្ហើម ឬបង្ហាញភស្តុតាងផ្សេងទៀតនៃជីវិត ដូចជាបេះដូងលោតមានជីពចរទងសុក ឬសាច់ដុំមានចលនាជាក់លាក់មិនថា ទងសុកត្រូវបានកាត់ផ្ដាច់ ឬមានជាប់សុកមកជាមួយក្ដី។

**ទិន្នន័យអត្តសញ្ញាណបុគ្គល** គឺជាព័ត៌មាននានាដែលអាចកំណត់បានអត្តសញ្ញាណបុគ្គលណាម្នាក់។

**បណ្ដឹងមិនសុខចិត្ត** គឺសំទៅដៅដល់បណ្ដឹងឧបាស្រ័យតាមផ្លូវរដ្ឋបាលរបស់បុគ្គលណាមួយដែលប្ដឹងចំពោះការចាត់ចែង រួមទាំងសេចក្ដីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់អាជ្ញាធរមានសមត្ថកិច្ច។

**ព័ត៌មានជីវមាត្រ** សំដៅដល់ការវាស់ស្ទង់លក្ខណៈជីវសាស្ត្រ និងលក្ខណៈផ្សេងទៀតមានដូចជាស្នាមខ្ចៅដៃ ប្រស្រីភ្នែក មុខ ហត្ថលេខា ឬសំឡេងជាអាទិ៍ ដែលអាចប្រមូលបានដោយឌីជីថល និងត្រូវបានប្រើប្រាស់សម្រាប់កំណត់អត្តសញ្ញាណរបស់បុគ្គលម្នាក់ៗ។

**បញ្ជីប្រជាជន** សំដៅទៅលើបណ្ដុំទិន្នន័យរបស់បុគ្គលម្នាក់ៗដូចជា នាម គោត្តនាម ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត សញ្ជាតិ ស្ថានភាពពលរដ្ឋ ស្ថានភាពអាពាហ៍ពិពាហ៍ ឈ្មោះឪពុកម្ដាយ កូន អាសយដ្ឋាន ទីសំណាក់ ព័ត៌មានជីវសាស្ត្រ និងទិន្នន័យអំពីឯកសារអត្តសញ្ញាណកម្មនានាដែលចេញឱ្យដោយអាជ្ញាធរ។

**ប្រព័ន្ធរួមអត្តសញ្ញាណកម្ម** គឺជាប្រព័ន្ធប្រតិបត្តិបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដែលមានមុខងារប្រមូលផ្ដុំទិន្នន័យពលរដ្ឋជាឌីជីថលសម្រាប់ឱ្យស្ថាប័នផ្សេងៗ និងសម្រាប់ប្រព័ន្ធរបស់ស្ថាប័ននោះប្រើប្រាស់ជាប្រភពទិន្នន័យពលរដ្ឋចម្បង និងតែមួយគត់។

**ប្រព័ន្ធគ្រប់គ្រងសញ្ជាតិ** គឺជាប្រព័ន្ធប្រតិបត្តិការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ហើយមានមុខងារគ្រប់គ្រង ប្រមូល បញ្ជូន រក្សាទុកទិន្នន័យការងារសញ្ជាតូបនីយកម្ម និងការលះបង់សញ្ជាតិខ្មែរ។

**ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន** ជាប្រព័ន្ធប្រតិបត្តិការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដែលមានមុខងារគ្រប់គ្រង ប្រមូល រក្សាទុកទិន្នន័យអត្រានុកូលដ្ឋាន ការផលិត និងចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទព្រមទាំងផលិតស្ថិតិអត្រានុកូលដ្ឋាន។

**ព្រឹត្តិការណ៍ជីវិត** គឺជាព្រឹត្តិការណ៍នៃកំណើតរស់ មរណភាព គភ៌ ការរៀប អាពាហ៍ពិពាហ៍ ការសុំកូនធម្មានុរូបកម្ម ការទទួលស្គាល់បុត្តភាព មោឃភាពអាពាហ៍ពិពាហ៍ ឬក៏ការលែងលះតាមផ្លូវច្បាប់ជាដើម។

**មរណភាព** គឺសំដៅដល់ការបាត់បង់ជាអចិន្ត្រៃយ៍នូវរាល់ភស្តុតាងនៃជីវិតនៅក្នុងពេលណាមួយក្រោយកំណើតរស់។

**មូលដ្ឋានសុខាភិបាល** គឺសំដៅទៅដល់មូលដ្ឋានសុខាភិបាលសាធារណៈ និងមូលដ្ឋានសុខាភិបាលឯកជនទាំងឡាយ។

**មូលដ្ឋានសុខាភិបាលឯកជន** សំដៅទៅដល់មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាក មន្ទីរសម្ភព រោគស្ត្រី និងគ្លីនិកឯកជន។

**លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព** សំដៅដល់ទម្រង់ដែលត្រូវបានបំពេញ ដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រដែលច្បាប់បានកំណត់ដើម្បីធ្វើការកត់ត្រាបញ្ជាក់អំពីមូលហេតុ និងប្រភេទនៃមរណភាពយោងតាមការចាត់ថ្នាក់ជំងឺជាលក្ខណៈអន្តរជាតិ។

**លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល** សំដៅដល់លេខកូដសម្រាប់សម្គាល់របស់បុគ្គលម្នាក់ៗ។

**សំបុត្រអត្រានុកូលដ្ឋាន** គឺជាសំបុត្រសម្រាប់កត់ត្រាភាពស៊ីវិលនៃពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់ក្នុងដែនសមត្ថកិច្ចកំណត់នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

**សហព័ទ្ធ** គឺប្តី ឬប្រពន្ធ ឬទាំងប្តីទាំងប្រពន្ធដែលទទួលបានឋានៈជាសហព័ទ្ធនេះក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។

**ស្ថិតិអត្រានុកូលដ្ឋាន** សំដៅដល់ស្ថិតិអំពីព្រឹត្តិការណ៍ជីវិតរបស់ពលរដ្ឋ។

**សំបុត្រអត្រានុកូលដ្ឋាន** គឺសំដៅទៅដល់ឯកសារនៅក្នុងទម្រង់ជាក្រដាស ឬអេឡិចត្រូនិកដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានដែលមានព័ត៌មានដូចគ្នាទាំងស្រុង ឬមួយផ្នែកនៃព័ត៌មាននៅក្នុងកំណត់ត្រានៃបញ្ជីអត្រានុកូលដ្ឋាន ហើយក្រោយពេលដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានរួចហើយនឹងត្រូវមានអានុភាព និងសុពលភាពពេញលេញដូចកំណត់ត្រានៃបញ្ជីអត្រានុកូលដ្ឋាន។

**អត្រានុកូលដ្ឋាន** គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្ដែងដែលជននោះមាននៅក្នុងត្រកូលគ្រួសារខ្លួន ក្នុងសង្គមជាតិ និងដែលបង្កើតឱ្យជននោះមានសិទ្ធិ និងករណីយកិច្ច។

**អត្តសញ្ញាណ** គឺជាលក្ខណៈមូលដ្ឋាននៃអត្តសញ្ញាណបុគ្គលរួមមាន ឈ្មោះ ភេទ ទីកន្លែងកំណើត និងថ្ងៃ ខែ ឆ្នាំកំណើត។

**អត្តសញ្ញាណកម្ម** សំដៅទៅដល់កិច្ចការរបស់រដ្ឋដែលធានាឱ្យប្រជាជនគ្រប់រូបកើតមានអត្តសញ្ញាណជាក់លាក់ខាងផ្លូវច្បាប់ ក្នុងគោលបំណងលើកកម្ពស់ការអនុវត្តសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បង្កើនប្រសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាជនជាដើម។

**អត្តសញ្ញាណខាងផ្លូវច្បាប់** គឺសំដៅទៅដល់លក្ខណៈជាមូលដ្ឋាននៃអត្តសញ្ញាណរបស់បុគ្គលរួមមាន ឈ្មោះ ភេទ ទីកន្លែងកំណើត និងថ្ងៃ ខែ ឆ្នាំកំណើត ដែលបានផ្តល់ និងចេញដោយមន្ត្រីអត្រានុកូលដ្ឋានតាមរយៈការចុះបញ្ជីកំណើតរស់។ នៅក្នុងករណីដែលគ្មានការចុះបញ្ជីកំណើតរស់ អត្តសញ្ញាណស្របច្បាប់អាចត្រូវបានផ្តល់ដោយអាជ្ញាធរអត្តសញ្ញាណកម្មដែលទទួលស្គាល់ដោយច្បាប់។

**អាពាហ៍ពិពាហ៍** គឺជាកិច្ចសន្យាដ៏ឱឡារិកដែលធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលបានប្ដេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិនៃច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានទៅតាមទំនើងចិត្តរបស់ខ្លួនឡើយ។

**អាសយដ្ឋានបច្ចុប្បន្ន** គឺជាទីតាំងលំនៅឋានដែលបុគ្គលកំពុងរស់នៅក្នុងភូមិសាស្ត្ររដ្ឋបាលជាក់លាក់ដូចមានលេខផ្ទះ ឈ្មោះផ្លូវ ក្រុម ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**អ្នករាយការណ៍** គឺជាបុគ្គល ឬស្ថាប័នដែលច្បាប់បានកំណត់ឱ្យរាយការណ៍ជូនមន្ត្រីអត្រានុកូលដ្ឋានដែលមានសមត្ថកិច្ចអំពីព្រឹត្តិការណ៍ជីវិតដែលបានកើតឡើង និងផ្តល់នូវរាល់ព័ត៌មាន និងចរិតលក្ខណៈទាំងអស់នៃព្រឹត្តិការណ៍នោះសម្រាប់ជាមូលដ្ឋានសម្រាប់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច អាចធ្វើការចុះបញ្ជីព្រឹត្តិការណ៍នោះតាមផ្លូវច្បាប់។

**ឯកជនភាព** សំដៅដល់ផ្នែកឯកជននៃជីវិតដែលបុគ្គលគ្រប់រូបមានសិទ្ធិទទួលបានការការពារ។

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាយើងបានឆ្លងកាត់របបនយោបាយជាច្រើន ហើយបានទទួលរងនូវវិបត្តិនយោបាយ និងសង្គ្រាមជាច្រើនទសវត្សរ៍ដែលធ្វើឱ្យប្រទេសយើងជួបផលវិបាកជាច្រើនក្នុងអំឡុងពេលសង្គ្រាម និងក្រោយពេលសង្គ្រាមត្រូវបានបញ្ចប់។ ទម្រង់បែបបទនានានៃការងារអត្រានុកូលដ្ឋានត្រូវបានបំផ្លាញទាំងស្រុងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ នៅដើមទសវត្សរ៍ទី៨០ ការងារអត្រានុកូលដ្ឋានត្រូវបានចាប់ផ្តើមឱ្យដំណើរការឡើងវិញ ប៉ុន្តែទម្រង់នៃអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅពេលនោះពុំទាន់ឯកភាពក្នុងទូទាំងប្រទេសនៅឡើយទេ។

អត្រានុកូលដ្ឋានមានសារៈសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋគ្រប់រូប និងប្រទេសជាតិ។ ការចុះបញ្ជីអត្រានុកូលដ្ឋានគឺជាការផ្តល់ឯកសារគតិយុត្តដ៏សំខាន់បំផុត សម្រាប់ប្រជាពលរដ្ឋដែលជាភស្តុតាងដ៏មានតម្លៃបំផុតក្នុងជីវិតរបស់មនុស្សម្នាក់ៗសម្រាប់បញ្ជាក់ពីអត្តសញ្ញាណ និងស្ថានភាពស៊ីវិលរបស់ខ្លួនក្នុងគោលបំណងលើកស្ទួយសិទ្ធិ ករណីយកិច្ច របស់ប្រជាពលរដ្ឋម្នាក់ៗ នៅក្នុងត្រកូលគ្រួសារ និងសង្គមជាតិ ព្រមទាំងប្រើប្រាស់ឯកសារអត្រានុកូលដ្ឋានសម្រាប់ការពារសិទ្ធិ សេរីភាព ផលប្រយោជន៍ និងកាតព្វកិច្ចនានា។ ប្រសិនបើគ្មានការចុះបញ្ជីអត្រានុកូលដ្ឋានបានត្រឹមត្រូវទេនោះនឹងនាំឱ្យមានបញ្ហាជាច្រើនដល់ប្រជាជន និងសង្គមជាតិផងដែរ។

ដោយយល់ឃើញពីសារៈប្រយោជន៍ដ៏សំខាន់ចាំបាច់ និងសេចក្តីត្រូវការជាបន្ទាន់ នៃអត្រានុកូលដ្ឋាន និងដើម្បីធ្វើឱ្យមានទម្រង់បែបបទ និងនីតិវិធីនៃការចុះអត្រានុកូលដ្ឋានមានឱ្យលក្ខណៈជាផ្លូវការ និងមានការឯកភាពគ្នាទូទាំងប្រទេស រាជរដ្ឋាភិបាលកម្ពុជាយើងបានដាក់ចេញនូវច្បាប់ អនុក្រឹត្យ សេចក្តីណែនាំជាច្រើនអំពីការចុះបញ្ជីអត្រានុកូលដ្ឋាន ដើម្បីធានា និងផ្តល់ឱ្យប្រជាពលរដ្ឋគ្រប់រូបមានអត្តសញ្ញាណខាងផ្លូវច្បាប់តាមរយៈការចុះបញ្ជីអត្រានុកូលដ្ឋាន ដោយផ្តល់ឱ្យចំពោះបុគ្គលម្នាក់ៗនូវលេខសម្គាល់អត្តសញ្ញាណបុគ្គល ព្រមទាំងធានានូវការគោរពសិទ្ធិមនុស្ស ហើយក៏ជាមូលដ្ឋានសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ និងការតាមដានភាពរីកចម្រើនរបស់សង្គមជាតិផងដែរ។

ដូច្នេះប្រជាពលរដ្ឋកម្ពុជាទាំងអស់គ្នាត្រូវមានតួនាទីដើម្បីធ្វើការស្នើសុំការចុះបញ្ជីអត្រានុកូលដ្ឋានរបស់ពួកគេនៅក្នុងសៀវភៅបញ្ជីអត្រានុកូលដ្ឋាន។ ការវិវត្តនៃលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងអត្រានុកូលដ្ឋានមានការផ្លាស់ប្តូរ កែប្រែ និងការណែនាំបន្ថែមជាច្រើនដែលជាហេតុធ្វើឱ្យការអនុវត្តមានភាពល្អប្រសើរឡើង ប៉ុន្តែនៅមានកង្វះខាតមួយចំនួននៅឡើយ ហើយរាជរដ្ឋាភិបាលកំពុងបន្តរៀបចំធ្វើយ៉ាងណាធានាឱ្យមានការចុះបញ្ជី

អគ្រានុកូលដ្ឋានជាកាតព្វកិច្ច ជាសកល ជាប់លាប់ និងជាអចិន្ត្រៃយ៍។ នៅក្នុងសារណាមួយនេះ ខ្ញុំបាទ និងនាងខ្ញុំ នឹងធ្វើការបកស្រាយទៅលើនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាននៅប្រទេសកម្ពុជាយើងនេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី **នីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាននៅកម្ពុជា** បាន ផ្តោតទៅលើបញ្ហាសំខាន់ចំនួន ០៣ គឺ៖

១. តើអ្វីជាអត្រានុកូលដ្ឋាន? មានសារៈសំខាន់ដូចម្តេចខ្លះ? ហើយមន្ត្រីមានសមត្ថកិច្ចលើកិច្ចការ អត្រានុកូលដ្ឋានមានតួនាទីដូចម្តេចខ្លះ?

២. តើប្រជាពលរដ្ឋត្រូវបំពេញលក្ខខណ្ឌ និងនីតិវិធីអ្វីខ្លះក្នុងការសុំចុះបញ្ជីអត្រានុកូលដ្ឋាន?

៣. តើមានបញ្ហាប្រឈមអ្វីខ្លះក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន? ហើយមានដំណោះស្រាយបែបណាខ្លះ ចំពោះបញ្ហាប្រឈមទាំងនោះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងដូចខាងក្រោម៖

១. ដើម្បីស្វែងយល់អំពីសារតា បែបបទ លក្ខខណ្ឌ ដំណើរការ និងនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន ព្រមទាំងបទដ្ឋានគតិយុត្តផ្សេងៗដែលពាក់ព័ន្ធនឹងអត្រានុកូលដ្ឋាន។

២. ដើម្បីស្វែងយល់អំពីការកែប្រែ ការបំពេញបន្ថែមផ្សេងៗដែលទាក់ទងនឹងអត្រានុកូលដ្ឋាន និងចង់ ចូលរួមចំណែកមួយក្នុងការដោះស្រាយបញ្ហាប្រឈមផ្សេងៗនៃការចុះបញ្ជីអត្រានុកូលដ្ឋាន។

៣. ចង់ឱ្យសាធារណៈជនបានយល់ដឹងឱ្យកាន់តែច្បាស់អំពីភាពចាំបាច់ និងសារៈសំខាន់ រួមទាំងនីតិវិធី នៃការចុះបញ្ជីអត្រានុកូលដ្ឋាន។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការតាក់តែងសារណាមួយនេះ ខ្ញុំបាទ និងនាងខ្ញុំ បានសិក្សាអំពីការចុះបញ្ជីអត្រានុកូលដ្ឋាននៅទូទាំង ប្រទេសកម្ពុជា ព្រមទាំងបានរំលេចនូវសារតានៃអត្រានុកូលដ្ឋានតាំងពីបុព្វកាលរហូតដល់បច្ចុប្បន្ន។ ប៉ុន្តែកិច្ច ការស្រាវជ្រាវមួយនេះផ្តោតសំខាន់ទៅលើការចុះបញ្ជីអត្រានុកូលដ្ឋាននាពេលបច្ចុប្បន្ន នៅទូទាំងប្រទេសកម្ពុជា អនុលោមទៅតាមច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម និងអនុក្រឹត្យ ប្រកាស សេចក្តីណែនាំ និងរបាយការណ៍ផ្សេងៗទាក់ទងនឹងអត្រានុកូលដ្ឋាន។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវមួយនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់ខ្ញុំបាទ និងនាងខ្ញុំដើម្បីទៅឈានដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឱ្យបានជោគជ័យ ព្រមទាំងបានពង្រឹង និងពង្រីកចំណេះដឹងដែលទាក់ទងទៅនឹងអត្រានុកូលដ្ឋានឱ្យកាន់តែប្រសើរ និងចំណេះដឹងនៅក្នុងការស្រាវជ្រាវ រួមទាំងទទួលបានបទពិសោធន៍ជាច្រើនពីកិច្ចការស្រាវជ្រាវមួយនេះ។ ជាពិសេសខ្ញុំបាទ និងនាងខ្ញុំសង្ឃឹមថាលទ្ធផលនៃការស្រាវជ្រាវប្រធានបទមួយនេះអាចទុកជាឯកសារមួយសម្រាប់បងប្អូនដែលជានិស្សិតជំនាន់ក្រោយៗធ្វើការសិក្សាស្វែងយល់បន្ថែមអំពីនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាននេះដើម្បីទទួលបានការយល់ដឹងកាន់តែច្បាស់ និងមានភាពត្រឹមត្រូវបន្ថែមទៀតផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវប្រធានបទមួយនេះ ខ្ញុំបាទ និងនាងខ្ញុំ បានធ្វើការប្រមូលទិន្នន័យឯកសារគតិយុត្តដូចជារដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ ប្រកាស សេចក្តីណែនាំ ដែលទាក់ទងនឹងអត្រានុកូលដ្ឋាន រួមទាំងឯកសារមួយចំនួនពីបណ្ណាល័យ និងមួយចំនួនទៀតតាមរយៈប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចនានា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្រោយពីបានប្រមូលឯកសារពាក់ព័ន្ធនានារួចមក ខ្ញុំបាទ និងនាងខ្ញុំ បានធ្វើបែងចែកប្រធានបទស្តីពីនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាននៅកម្ពុជា នេះជាពីរជំពូកដូចខាងក្រោម៖

**ជំពូកទី១ សញ្ញាណទូទៅនៃអត្រានុកូលដ្ឋាន** នៅក្នុងជំពូកទី១នេះចែកជា៤ចំណុចទៀត គឺចំណុចទី១ សារតានៃអត្រានុកូលដ្ឋាន, ចំណុចទី២ ប្រភេទនៃអត្រានុកូលដ្ឋាន, ចំណុចទី៣ សារៈសំខាន់នៃអត្រានុកូលដ្ឋាន និងចំណុចទី៤ មន្ត្រីមានសមត្ថកិច្ចនៃអត្រានុកូលដ្ឋាន។

**ជំពូកទី២ នីតិវិធីនៃការសុំចុះបញ្ជីអត្រានុកូលដ្ឋាន** កំណើត អាពាហ៍ពិពាហ៍ និងមរណភាព នៅក្នុងជំពូកនេះចែកជា៣ចំណុចទៀត គឺចំណុចទី១ ការសុំចុះបញ្ជីអត្រានុកូលដ្ឋាន និងសៀវភៅអត្រានុកូលដ្ឋាន, ចំណុចទី២ សេចក្តីចម្លងអត្រានុកូលដ្ឋាន និងការជូនដំណឹងនៃអត្រានុកូលដ្ឋាន, ចំណុចទី៣ បញ្ហាប្រឈម និងដំណោះស្រាយនៃការចុះបញ្ជីអត្រានុកូលដ្ឋាន។

# ជំពូកទី១

# សញ្ញាណទូទៅនៃអត្រានុកូលដ្ឋាន

# ជំពូកទី១

# សញ្ញាណទូទៅនៃអត្រានុកូលដ្ឋាន

## ១.១. សាវតានៃអត្រានុកូលដ្ឋាន

### ១.១.១. នៅមុនឆ្នាំ១៩៩៣

យោងទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ គឺបានបង្ហាញថាប្រទេសកម្ពុជាយើងធ្លាប់មានមូលដ្ឋានច្បាប់ និងការចុះបញ្ជីអត្រានុកូលដ្ឋានតាំងពីមុនសម័យសង្គ្រាមស៊ីវិលមកម្ល៉េះ។ អត្រានុកូលដ្ឋាន នៅសម័យនោះ គឺជាបញ្ជីសម្រាប់កត់ជំរឿនមនុស្សដែលរស់នៅក្នុងប្រទេសឱ្យដឹងថាឆ្នាំណាមានមនុស្សប៉ុន្មាននាក់ៗ និងនៅសង្កាត់នីមួយៗដែលរួមទៅមនុស្សចំណុះស្រុក និងចំណុះខេត្ត។ មិនត្រឹមតែប៉ុណ្ណោះបញ្ជីនេះត្រូវកត់ត្រានូវចំនួនមនុស្សកើត មនុស្សរៀបអាពាហ៍ពិពាហ៍ និងមនុស្សទទួលមរណភាព។[1] នៅសម័យមុនគេបានហៅសំបុត្រកំណើតថាជាសញ្ញាបត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ហៅថាសញ្ញាបត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាពហៅថាសញ្ញាបត្រមរណភាព។ ចំពោះអត្រានុកូលដ្ឋានសញ្ញាបត្រនីមួយៗ ទុកជាសញ្ញាបត្រត្រឹមត្រូវបានលុះត្រាតែបានធ្វើនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។[2] អ្នកដែលមានសិទ្ធិអំណាចកាន់បញ្ជីអត្រានុកូលដ្ឋាន គឺមេសង្កាត់ដែលត្រូវចម្លងបញ្ជីនេះជាពីរច្បាប់ទុកនៅសាលាស្រុកមួយច្បាប់ និងនៅសាលាដំបូងមួយច្បាប់។ ចំពោះជនណាដែលមានកាតព្វកិច្ចត្រូវប្តឹងកំណើត និងមរណភាព ក៏ប៉ុន្តែភ្លេច ឬធ្វេសប្រហែសមិនបានប្តឹងដោយឥតហេតុដ៏គួរជននោះនឹងត្រូវទទួលទណ្ឌកម្មជាលហុទោស។[3] នៅពេលណាមានទារកកើតត្រូវចុះបញ្ជីអត្រានុកូលដ្ឋាននៅក្នុងរយៈពេល ១៥ថ្ងៃ ចំពោះការចុះបញ្ជីអត្រានុកូលដ្ឋានមរណភាពកំណត់រយៈពេល ០៣ថ្ងៃ ហើយបើហួសថ្ងៃកំណត់នេះត្រូវសុំសាលក្រមពីសាលាដំបូង។ ដោយយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ១៩២០នេះ គឺបានបង្ហាញឱ្យឃើញថាប្រទេសកម្ពុជាយើងធ្លាប់មានមូលដ្ឋានច្បាប់ និងការចុះបញ្ជីអត្រានុកូលដ្ឋាននេះជាយូរមកហើយ។ ប្រទេសកម្ពុជាយើងបានឆ្លងកាត់សង្គ្រាមជាច្រើនសម័យកាលដែលធ្វើឱ្យការអនុវត្តច្បាប់មានការលំបាក។ នៅឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ប្រទេសកម្ពុជាស្ថិតក្នុងសង្គ្រាមស៊ីវិលធ្វើឱ្យប្រទេសជាតិមានភាពវឹកវរ ជួបវិបត្តិផ្ទៃក្នុងដែលជាហេតុធ្វើឱ្យការចុះបញ្ជីអត្រានុកូលដ្ឋានជួបប្រទះនូវបញ្ហាប្រឈមជាច្រើន រហូតឈានទៅដល់ការប្រមូលសៀវភៅបញ្ជីអត្រានុកូលដ្ឋានយកទៅរក្សាទុកនៅក្នុងក្រសួងយុត្តិធម៌។ ក្រោយមកទៀតនៅក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ គឺសម័យកម្ពុជាប្រជាធិបតេយ្យជារបបប្រល័យពូជសាសន៍ និងជារបបខ្មៅងងឹតបានធ្វើឱ្យការងារអត្រានុកូលដ្ឋាន

[1] សៀវភៅ លោកនីតិ, លី ធាមតេង, បោះពុម្ពឆ្នាំ១៩៦៧, ទំព័រទី១

[2] ក្រមរដ្ឋប្បវេណី, ឆ្នាំ១៩២០, មាត្រា៣០

[3] ក្រមរដ្ឋប្បវេណី, ឆ្នាំ១៩២០, មាត្រា៤៤

ត្រូវបញ្ចប់ទាំងស្រុងហើយសៀវភៅអត្រានុកូលដ្ឋាន ព្រមទាំងប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លីក៏ត្រូវបានបំផ្លាញចោលទាំងអស់។ របបកម្ពុជាប្រជាធិបតេយ្យត្រូវបានបញ្ចប់នៅក្នុងឆ្នាំ១៩៧៩ ការងារអត្រានុកូលដ្ឋានក៏បានចាប់ផ្តើមឡើងវិញ ប៉ុន្តែនៅមិនទាន់បានឯកភាពគ្នាទូទាំងប្រទេសទេ រហូតដល់ឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានបោះឆ្នោតជាសកលដែលរៀបចំឡើងដោយ អ៊ុន តាក់ ហើយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលធ្វើឱ្យស្ថានភាពប្រទេសកាន់តែប្រសើរឡើង ហើយការរៀបចំការងារអត្រានុកុលដ្ឋានក៏ចាប់ផ្តើមល្អប្រសើរឡើង។

### ១.១.២. ក្រោយឆ្នាំ១៩៩៣ដល់បច្ចុប្បន្ន

ក្រោយឆ្នាំ១៩៩៣ មកស្ថានភាពប្រទេសកាន់តែប្រសើរ រហូតដល់ឆ្នាំ១៩៩៨ ប្រទេសកម្ពុជាទទួលបានសន្តិភាពពេញលេញ រដ្ឋាភិបាលខិតខំស្តារប្រទេសជាតិឡើងវិញ។ នៅឆ្នាំ២០០០ អនុក្រឹត្យលេខ ១០៣ ស្តីពីអត្រានុកូលដ្ឋានត្រូវបានបង្កើតឡើងដែលមានអនុភាពទូទាំងប្រទេស អនុក្រឹត្យនេះត្រូវបានដាក់ឱ្យអនុវត្តនៅថ្ងៃទី២ ខែសីហា ឆ្នាំ២០០២ ការអនុវត្តអនុក្រឹត្យនេះបានជួបនូវបញ្ហាជាច្រើនដែលតម្រូវឱ្យរាជរដ្ឋាភិបាលចេញនូវអនុក្រឹត្យកែសម្រួលអនុក្រឹត្យលេខ ១០៣នេះ និងបានចេញប្រកាស សេចក្តីណែនាំផ្សេងៗជាច្រើនបន្តបន្ទាប់។ រាជរដ្ឋាភិបាលបានខិតខំធ្វើយ៉ាងណាដើម្បីឱ្យការងារអត្រានុកូលដ្ឋានកាន់តែប្រសើរឡើង ដោយបង្កើតជាច្បាប់ និងបទដ្ឋានគតិយុត្តិជាច្រើន។ រហូតមកដល់ឆ្នាំ២០២៣ ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មត្រូវបានបង្កើតឡើង និងដាក់ឱ្យអនុវត្តជាទូទៅនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ថ្មីៗនេះ។ ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម បានកំណត់អំពីវិធាន និងនីតិវិធីដែលទាក់ទងនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន ការចុះបញ្ជីស្នាក់នៅ ការរៀបចំស្ថិតិអត្រានុកូលដ្ឋាន ការចុះបញ្ជីអត្តសញ្ញាណបុគ្គល ការរៀបចំ និងការគ្រប់គ្រងបញ្ជីប្រជាជន ក្នុងគោលបំណងដើម្បីធានា ឱ្យមានការចុះបញ្ជីអត្រានុកូលដ្ឋានជាកាតព្វកិច្ច ជាសកល ដោយជាប់លាប់ និងជាអចិន្ត្រៃយ៍ ដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូបមានអត្តសញ្ញាណខាងផ្លូវច្បាប់តាមរយៈការចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះបញ្ជីអត្តសញ្ញាណដោយផ្តល់ឱ្យចំពោះបុគ្គលម្នាក់ៗនូវលេខសម្គាល់អត្តសញ្ញាណបុគ្គល ធានានូវការគោរពសិទ្ធិមនុស្ស ការទទួលបានសេវាគ្រប់ប្រភេទ ហើយជាមូលដ្ឋានសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ និងការតាមដានភាពរីកចម្រើននៃសង្គមជាតិ។[4] ហើយច្បាប់នេះមានវិសាលភាពអនុវត្តចំពោះជនគ្រប់រូបដែលរស់នៅលើទឹកដីកម្ពុជា និងប្រជាពលរដ្ឋខ្មែរដែលរស់នៅបរទេស។[5]

[4] ច្បាប់ ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, ព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា១

[5] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា២

## ១.២. ប្រភេទនៃអត្រានុកូលដ្ឋាន

អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែងដែលជននោះមាននៅក្នុងត្រកូលគ្រួសារខ្លួន ក្នុងសង្គមជាតិ ដែលបង្កើតឱ្យជននោះមានសិទ្ធិ និងករណីយកិច្ច។ បញ្ជីអត្រានុកូលដ្ឋានរបស់បុគ្គលម្នាក់សំដៅទៅលើស្ថានភាពបីគឺ បញ្ជីកំណើតរស់ បញ្ជីអាពាហ៍ពិពាហ៍ និងបញ្ជីមរណៈភាព។[6]

### ១.២.១.អត្រានុកូលដ្ឋានកំណើត

រាល់កំណើតដែលកើតក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរាយការណ៍ និងចុះបញ្ជីតាមបទប្បញ្ញត្តនៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។ អត្រានុកូលដ្ឋានកំណើតមាន២ប្រភេទ គឺសំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត។

#### ១.២.១.១. សំបុត្រកំណើត

កំណើត គឺជាព្រឹត្តិការណ៍គតិយុត្តមួយដែលនាំឱ្យកើតមាននូវរូបវន្តបុគ្គល គឺជាការចាប់ផ្តើមកកើតសិទ្ធិ និងកាតព្វកិច្ចរបស់រូបវន្តបុគ្គលម្នាក់ៗដែលកើតមករស់ ហើយមានជីវិតរស់នៅបាន។ បើមានទារកកើត ឪពុក ឬម្តាយមានកាតព្វកិច្ចត្រូវទៅរាយការណ៍សុំចុះសៀវភៅកំណើត នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំ ឬសង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុកម្តាយរបស់ទារកនោះ ប៉ុន្តែបើឪពុកម្តាយរបស់ទារកមានធុរៈមិនបានទៅត្រូវពឹងពាក់សាច់ញាតិឱ្យទៅសុំចុះបញ្ជីកំណើតទារកដែលបានកើតនោះឱ្យទាន់ពេលកំណត់។ ចំពោះការសុំចុះបញ្ជីត្រូវបញ្ជាក់ឱ្យច្បាស់ថាឪពុក និងម្តាយរបស់ទារកនោះមានខាន់ស្លា ឬឥតខាន់ស្លា បើមានខាន់ស្លាត្រូវបង្ហាញសំបុត្រអាពាហ៍ពិពាហ៍របស់ឪពុកម្តាយរបស់ទារកនោះ។[7] ក្រោយពេលមន្ត្រីអត្រានុកូលដ្ឋានទទួលយក និងកត់ត្រាព័ត៌មានដែលទាក់ទងនឹងកំណើតរស់រួចមកមន្ត្រីអត្រានុកូលដ្ឋានត្រូវស្នើទៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននៃអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជនដើម្បីផ្តល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលដល់អ្នកកើត។ ក្រោយពេលទទួលបានលេខសម្គាល់អត្តសញ្ញាណបុគ្គលមន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់លេខកូដសម្គាល់បុគ្គលរបស់អ្នកកើតនោះទៅឱ្យអ្នករាយការណ៍។ ក្រោយពេលចុះបញ្ជីកំណើតរួចរាល់តាមរយៈពេលកំណត់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវចេញសំបុត្រកំណើតច្បាប់ដើម ០១ច្បាប់ជូនអ្នករាយការណ៍សុំចុះបញ្ជីកំណើតដោយឥតគិតថ្លៃ។ បញ្ជីកំណើតដែលបានចុះក្នុងរយៈពេលកំណត់ ៣០ថ្ងៃត្រូវហៅថាសំបុត្រកំណើតដែលមន្ត្រីអត្រានុកូលដ្ឋានបានផ្តល់ឱ្យ។

---

[6] អនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា២

[7] អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា១៧

### ១.២.១.២. សំបុត្របញ្ជាក់កំណើត

ប្រសិនបើអ្នករាយការណ៍ មិនបានដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ក្នុងរយៈពេល ៣០ថ្ងៃគិតចាប់ពីថ្ងៃដែលទារកនោះកើត អ្នករាយការណ៍ត្រូវសុំចុះបញ្ជីកំណើតក្នុងរយៈពេលអនុគ្រោះមួយឆ្នាំគិតចាប់ពីថ្ងៃដែលទារកកើតដោយបញ្ជាក់ពីមូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីក្នុងរយៈពេល ៣០ថ្ងៃ។ បើអ្នករាយការណ៍មិនបានដាក់ពាក្យសុំចុះបញ្ជីរស់ក្រោយផុតរយៈពេលអនុគ្រោះមួយឆ្នាំ អ្នករាយការណ៍ត្រូវផ្តល់ព័ត៌មាន ឬឯកសារបន្ថែមដូចជា ការធានាអះអាងនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានរបស់សាក្សីនៃកំណើតរស់នេះ ប័ណ្ណសុខភាពកុមារ ឯកសារ ឬព័ត៌មានផ្សេងទៀតដែលបញ្ជាក់អំពីព្រឹត្តការណ៍កំណើតរស់ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តិរបស់ក្រសួងមហាផ្ទៃ។[8]

បើមានទារកណាម្នាក់កើតហើយទុកឱ្យហួសរយៈពេល ៣០ថ្ងៃ មិនបានទៅរាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតទេ ឪពុក ឬម្តាយ ឬអាណាព្យាបាលត្រូវសុំប្តឹងសុំសំបុត្រកំណើតនេះពីមេឃុំ ចៅសង្កាត់សាមីដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្នដោយនាំទៅជាមួយនូវសាក្សីចំនួន២រូបជានីតិជន ហើយត្រូវមានលំនៅពិតប្រាកដមកបញ្ជាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ការប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត សាមីខ្លួន ឬឪពុកម្តាយ ឬអាណាព្យាបាល ត្រូវបង់ថ្លៃ១០០០រៀលសម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅ នៅក្នុងខេត្តរតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ ឧត្តមានជ័យ និងបង់ថ្លៃ៤០០០រៀលសម្រាប់ប្រជាជនដែលមានទីលំនៅក្រៅពីខេត្តខាងលើ។[9] ការប្តឹងសុំចុះបញ្ជីកំណើតរស់ដែលទុកឱ្យហួសរយៈពេល ៣០ថ្ងៃមន្ត្រីអត្រានុកូលដ្ឋាននឹងចេញសំបុត្របញ្ជាក់កំណើតឱ្យដែលយើងហៅថាសំបុត្របញ្ជាក់កំណើត។

ពលរដ្ឋខ្មែរដែលកើតមុនពេលមានអនុក្រឹត្យលេខ ១០៣ ស្តីពីអត្រានុកូលដ្ឋានចូលជាធរមានហើយគ្មានសំបុត្រកំណើតប្រើប្រាស់ អាចសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតបានតាមគំរូណែនាំថ្មី នៅសាលាឃុំ សង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន២រូបជានីតិជន ហើយត្រូវមានទីលំនៅពិតប្រាកដនាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីក្រសួងស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះ

[8] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៣៩

[9] កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន, ទំព័រទី១១

សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត មិនត្រូវឱ្យខុសពីថ្ងៃ ខែ ឆ្នាំកំណើតដែលមាននៅក្នុងឯកសារបៀវត្ស ឬសោធននិវត្តន៍ជាផ្លូវការឡើយ។[10]

### ១.២.២. អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកដែលធ្វើឡើងដោយបុរសម្នាក់ និងស្រ្តីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួនឡើយ។ ចំពោះការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីហើយតែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍មិនមែនជាការរៀបអាពាហ៍ពិពាហ៍ស្របតាមផ្លូវច្បាប់នោះទេ។ នៅក្នុងឯកសារនេះការប្រើពាក្យថា អាពាហ៍ពិពាហ៍ មានន័យថា អាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ឬការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្រ្តីអត្រានុកូលដ្ឋាន។[11]

#### ១.២.២.១. សំបុត្រអាពាហ៍ពិពាហ៍

បុរស និងនារី ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្រ្តីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់នៃលំនៅដ្ឋានសាមីខ្លួនខាងនារី។ មន្រ្តីអត្រានុកូលដ្ឋាន ត្រូវពិនិត្យឱ្យបានហ្មត់ចត់នូវពាក្យសុំនោះដោយផ្អែក ទៅលើលក្ខខណ្ឌនៃច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។ មន្រ្តីអត្រានុកូលដ្ឋានត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ដែលគ្រោងនឹងធ្វើនោះ ត្រូវបិទផ្សាយជាសាធារណៈនៅលំនៅដ្ឋាន និងនៅសាលាឃុំ ឬសាលាសង្កាត់នៃសាមីខ្លួននារីចំនួន ០១ច្បាប់។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ចំនួន ០២ច្បាប់ទៀតត្រូវផ្ញើទៅជូនមន្រ្តីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និងបិទនៅសាលាឃុំ ឬសង្កាត់ នៃសាមីខ្លួនបុរសចំនួន ០១ច្បាប់ ។

អាពាហ៍ពិពាហ៍ត្រូវចាត់ទុកថាស្របច្បាប់ លុះត្រាណាតែបុរស និងនារីបានចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្រ្តីអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ដែលបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះ។ ព័ត៌មាន ឬចំណុចដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ ត្រូវបញ្ចូលទៅក្នុងបញ្ជីអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្រ្តីអត្រានុកូលដ្ឋាន និងចុះហត្ថលេខា ឬផ្តិតស្នាមមេដៃដោយបុគ្គលដែលមានបំណងធ្វើជាសហព័ទ្ធ និងដោយមានសាក្សីចំនួន ០២រូបជានីតិជន។ ក្រោយពេលដែលចុះបញ្ជីអាពាហ៍ពិពាហ៍រួចរាល់ មន្រ្តីអត្រានុកូលដ្ឋានមាន

---

[10] អនុក្រឹត្យ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ ១៧ អនក្រ.បក, ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤, មាត្រា៤៣ថ្មី

[11] កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន, ទំព័រទី១

សមត្ថកិច្ចត្រូវចេញសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម ០១ច្បាប់ ជូនប្តីប្រពន្ធនោះដោយឥតគិតថ្លៃដែលយើងហៅថាសំបុត្រអាពាហ៍ពិពាហ៍។[12]

#### ១.២.២.២. សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

ពលរដ្ឋខ្មែរដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ នៅមុនពេលដែលមាន អនុក្រឹត្យលេខ ១០៣ ស្តីពីអត្រានុកូលដ្ឋាន ចូលជាធរមាន ហើយមិនទាន់បានចុះសៀវភៅអាពាហ៍ពិពាហ៍ សាមីខ្លួនទាំងពីររូបអាចស្នើសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មី នៅសាលាឃុំ ឬសង្កាត់ដែលខ្លួនបានរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២ រូបជានីតិជន និងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។[13] ការសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍នេះមន្ត្រីអត្រានុកូលដ្ឋាននឹងចេញសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើមឱ្យទៅប្តីប្រពន្ធនោះមួយច្បាប់ ដែលយើងហៅថាសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍។

### ១.២.៣. អត្រានុកូលដ្ឋានមរណភាព

រាល់មរណភាពដែលកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរាយការណ៍ និងចុះបញ្ជីដោយយោងទៅតាមច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

#### ១.២.៣.១. សំបុត្រមរណភាព

នៅពេលដែលមានបុគ្គលណាម្នាក់ទទួលមរណភាព ឪពុកម្តាយ ឬសហព័ទ្ធ ឬញាតិជានីតិជនរបស់មរណជនត្រូវរាយការណ៍អំពីមរណភាព ត្រូវដាក់ពាក្យសុំចុះបញ្ជីមរណភាពក្នុងរយៈពេល ១៥ថ្ងៃគិតចាប់ពីកាលបរិច្ឆេទដែលព្រឹត្តិការណ៍មរណភាពបានកើតឡើង។ ក្រោយពេលចុះបញ្ជីមរណភាពរួចរាល់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវចេញសំបុត្រមរណភាពច្បាប់ដើមមួយច្បាប់ជូនដល់អ្នករាយការណ៍ដោយឥតគិតថ្លៃ។ ក្រោយពេលចុះបញ្ជីមរណភាពរួច មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិត្រូវធានាឱ្យមានការ ផ្ទៀងផ្ទាត់រវាងបញ្ជីមរណភាពទៅនឹងបញ្ជីអត្រានុកូលដ្ឋានផ្សេងទៀតរបស់មរណជនដើម្បីចុះនិទ្ទេស នៅក្នុងបញ្ជីអត្រានុកូលដ្ឋានផ្សេងទៀតនោះថាបុគ្គលនោះបានទទួលមរណភាព។ ក្រោយពេលចុះនិទ្ទេស នៅក្នុងបញ្ជីអត្រានុកូលដ្ឋានផ្សេងទៀតរួចហើយ ប្រសិនបើមានការស្នើសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានផ្សេងទៀតរបស់មរណជន ក្នុងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានផ្សេងទៀតនោះត្រូវសរសេរបញ្ជាក់ថាស្លាប់។ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិត្រូវផ្តល់ព័ត៌មានជូនមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននៃអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន។

[12] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៧០-៧១

[13] អនុក្រឹត្យលេខ ១៧ អនក្រ.បក, ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤, មាត្រា៤5ថ្មី

មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណ ប្រជាជននៃអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន ត្រូវបិទលេខកូដសម្រាប់កំណត់សម្គាល់អត្តសញ្ញាណ បុគ្គលរបស់មរណជន (ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន) នៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។[14] ការដាក់ពាក្យសុំចុះបញ្ជីមរណភាពនៅក្នុងរយៈពេល ១៥ថ្ងៃគិតចាប់ពីកាលបរិច្ឆេទដែលព្រឹត្តិការណ៍មរណភាពបានកើតឡើងនឹងទទួលបានសំបុត្រមរណភាព។

### ១.២.៣.២. សំបុត្របញ្ជាក់មរណភាព

នៅពេលមន្ត្រីអត្រានុកូលដ្ឋាន បានដឹងថាមានព្រឹត្តិការណ៍មរណភាពមួយបានកើតឡើងតាមរយៈការជូនដំណឹងពីអាជ្ញាធរពាក់ព័ន្ធ ឬប្រភពផ្សេងទៀត ហើយអ្នករាយការណ៍មិនបានដាក់ពាក្យសុំចុះបញ្ជីមរណភាពក្នុងរយៈពេល១៥ថ្ងៃទេនោះមន្ត្រីអត្រានុកូលដ្ឋាន ត្រូវដាស់តឿនដល់អ្នករាយការណ៍ឱ្យមកធ្វើការដាក់ពាក្យសុំចុះបញ្ជីមរណភាពដោយកំណត់រយៈពេលសមស្របណាមួយ។ ប្រសិនបើអ្នករាយការណ៍មិនបានដាក់ពាក្យសុំចុះបញ្ជីមរណភាពក្នុងរយៈពេល ១៥ថ្ងៃគិតចាប់ពីកាលបរិច្ឆេទដែលព្រឹត្តិការណ៍មរណភាពបានកើតមានឡើងនោះអ្នករាយការណ៍ត្រូវដាក់ពាក្យសុំចុះបញ្ជីមរណភាពនៅក្នុងរយៈពេលអនុគ្រោះមួយឆ្នាំដែលគិតចាប់ពីកាលបរិច្ឆេទដែលព្រឹត្តិការណ៍មរណភាពនោះបានកើតឡើង។ អ្នករាយការណ៍ក៏ត្រូវភ្ជាប់មកជាមួយឯកសារដែលបញ្ជាក់អំពីមូលហេតុនៃការមិនបានដាក់ពាក្យសុំចុះបញ្ជីក្នុងរយៈពេល ១៥ថ្ងៃក្រោយពេលដែលមរណភាពបានកើតឡើង។ ប្រសិនបើអ្នករាយការណ៍ មិនបានដាក់ពាក្យសុំចុះបញ្ជីមរណភាពក្រោយផុតរយៈពេលអនុគ្រោះមួយឆ្នាំទេនោះ អ្នករាយការណ៍ត្រូវផ្តល់ព័ត៌មាន ឬឯកសារបន្ថែមដូចជាការធានាអះអាងនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានរបស់សាក្សីនៃមរណភាព ឯកសារ ឬព័ត៌មានផ្សេងៗទៀតដែលអាចបញ្ជាក់អំពីព្រឹត្តិការណ៍នៃមរណភាព ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ ហើយអ្នករាយការណ៍ត្រូវភ្ជាប់មកជាមួយឯកសារបញ្ជាក់អំពីមូលហេតុនៃការដែលមិនបានដាក់ពាក្យសុំចុះបញ្ជីក្នុងរយៈពេលអនុគ្រោះមួយឆ្នាំផងដែរ។ នៅពេលដែលទទួលបានព័ត៌មាន និងឯកសារខាងលើនេះរួចហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើការចុះបញ្ជីមរណភាពនោះ ដោយចេញសំបុត្របញ្ជាក់មរណភាពច្បាប់ដើមមួយច្បាប់ជូនអ្នករាយការណ៍នោះ។[15]

ប្រជាពលរដ្ឋខ្មែរដែលបានស្លាប់មុនពេលដែលអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានចូលជាធរមានហើយគ្មានសំបុត្រមរណភាពទេនោះសាច់ញាតិសន្តានដែលនៅរស់ អាចមកសុំចុះសៀវភៅបញ្ជាក់មរណភាពបានតាមគំរូណែនាំថ្មីនៅសាលាឃុំ ឬសង្កាត់ ដែលញាតិសន្តានរស់នៅជាប់លាប់បច្ចុប្បន្ន ដោយត្រូវនាំសាក្សីចំនួន ០២រូប

[14] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៥៨

[15] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៦៤-៦៥

ជានីតិជន ហើយមានទីលំនៅពិតប្រាកដមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។[16] បើមានអ្នកស្លាប់ ហើយទុកឱ្យហួសរយៈពេល ១៥ថ្ងៃនៅក្នុងឆ្នាំ និងពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារនៃមរណជនត្រូវដាក់ពាក្យប្ដឹងសុំសំបុត្រមរណភាពពីមេឃុំ ចៅសង្កាត់នៃលំនៅឋាន ពិតប្រាកដរបស់អ្នកស្លាប់។ ចំពោះការប្ដឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៃមរណជនណាម្នាក់ ត្រូវបង់ថ្លៃចំនួន ១.០០០រៀល សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅ នៅក្នុងខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ឧត្តរមានជ័យ ព្រះវិហារ និងបង់ថ្លៃ ៤.០០០រៀលសម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅក្រៅពីខេត្តខាងលើ។[17] បើមានអ្នកស្លាប់ហើយទុកឱ្យហួសឆ្នាំពុំបានទៅរាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសាររបស់មរណជនត្រូវប្ដឹងសុំសាលក្រមពីសាលាដំបូងរាជធានី ខេត្ត រួចយកសាលក្រមនោះមកសុំមន្ត្រីអត្រានុកូលដ្ឋាន ឃុំ សង្កាត់នៃអ្នកស្លាប់ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព។ ការសុំចុះបញ្ជីមរណភាពហួសពេលរយៈ ១៥ថ្ងៃចាប់ពីកាលបរិច្ឆេទដែលព្រឹត្តិការណ៍មរណភាពបានកើតឡើង និងពលរដ្ឋខ្មែរដែលស្លាប់នៅមុនពេលមានអនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន ចូលជាធរមាន ហើយគ្មានសំបុត្រមរណភាព សាច់ញាតិសន្តាន ដែលនៅរស់អាចមកសុំចុះសៀវភៅបញ្ជាក់មរណភាពបាន មន្ត្រីអត្រានុកូលដ្ឋាននឹងផ្ដល់សំបុត្របញ្ជាក់មរណភាពជូន។[18]

## ១.៣. សារៈសំខាន់នៃអត្រានុកូលដ្ឋាន

អត្រានុកូលដ្ឋានមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រជាពលរដ្ឋ និងប្រទេសជាតិ។ ប្រជាពលរដ្ឋទាំងអស់ត្រូវចុះសំបុត្រអត្រានុកូលដ្ឋាន ដើម្បីទទួលបានសិទ្ធិពេញលេញជាពលរដ្ឋខ្មែរស្របច្បាប់ រួមមានសិទ្ធសេដ្ឋកិច្ច សង្គមកិច្ច សិទ្ធិនយោបាយ សិទ្ធិទទួលបានការអប់រំ និងការងារ សិទ្ធិកាន់កាប់កម្មសិទ្ធ សិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត ព្រមទាំងសិទ្ធិទទួលបាននូវយុត្តិធម៌ និងការជំនុំជម្រះក្ដីដោយយុត្តិធម៌ផងដែរ។ អត្រានុកូលដ្ឋានជាកត្តាសំខាន់មួយចូលរួមចំណែកនៅក្នុងការអភិវឌ្ឍប្រទេសជាតិ រួមចំណែកធានានូវការអនុវត្តច្បាប់ និងផែនការអភិវឌ្ឍន៍ប្រទេសជាតិ បើប្រជាពលរដ្ឋបានចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ៗរូបនោះនឹងផ្ដល់ភាពងាយស្រួលដល់រដ្ឋាភិបាលនៅក្នុងការគ្រប់គ្រងស្ថិតិប្រជាជន និងការរៀបចំផែនការអភិវឌ្ឍន៍ប្រទេសជាតិដើម្បីទទួលបានប្រសិទ្ធិភាពខ្ពស់ផងដែរ។

---

[16] អនុក្រឹត្យលេខ ១៧ អនក្រ.បក, ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤, មាត្រា៤៧ថ្មី

[17] អនុក្រឹត្យលេខ ១៧ អនក្រ.បក, ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤, មាត្រា៤០ថ្មី

[18] កម្រងឯកសារស្ដីពី របៀបកត់ត្រាការងារអត្រានុកូលដ្ឋាន, ទំព័រទី១២៥-126

### ១.៣.១. សារៈសំខាន់នៃអត្រានុកូលដ្ឋានកំណើត

អត្រានុកូលដ្ឋានកំណើតសំដៅដល់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត គឺជាអត្រានុកូលដ្ឋានដំបូងគេដែលបានកំណត់ និងបញ្ជាក់ពីឈ្មោះ នាមត្រកូល ភេទ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយ របស់បុគ្គលម្នាក់។ អត្រានុកូលដ្ឋានកំណើតមានសារៈសំខាន់ជាច្រើនដូចជា៖

- ធ្វើឱ្យរូបវន្តបុគ្គលម្នាក់ចាប់ផ្តើមទទួលបានសិទ្ធិ និងករណីយកិច្ច។
- មានសិទ្ធិទទួលបានការអប់រំ។
- មានសិទ្ធិទទួលបានការថែទាំសុខភាព។
- មានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិលើដីធ្លីនៅកម្ពុជា បើមានសញ្ជាតិខ្មែរពីកំណើត។
- អាចយកទៅចុះឈ្មោះចូលរៀនដំបូងនៅសាលារដ្ឋ។
- សិទ្ធិមិនអាចជាប់ពន្ធនាគារសម្រាប់អនីតិជនអាយុក្រោម១៤ឆ្នាំ។
- អាចយកទៅធ្វើលិខិតឆ្លងដែន។
- ទទួលបានសិទ្ធិជាពលរដ្ឋពេញលេញ មានសិទ្ធិសេរីភាពស្មើគ្នាចំពោះមុខច្បាប់។
- អាចយកទៅធ្វើអត្តសញ្ញាណប័ណ្ណខ្មែរនៅពេលមានអាយុ ១៥ឆ្នាំ។
- អាចយកទៅធ្វើសៀវភៅគ្រួសារ សៀវភៅស្នាក់នៅ។
- អាចយកទៅប្រើប្រាស់ក្នុងការចូលបម្រើការងារផ្សេងៗ។
- មានសិទ្ធិទទួលបានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ។
- និងអាចយកទៅប្រើប្រាស់ចំពោះតម្រូវការចាំបាច់ផ្សេងៗទៀត។

### ១.៣.២. សារៈសំខាន់នៃអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍

អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ សំដៅដល់សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ដែលជាឯកសារ ជាភស្តុតាង ដែលបញ្ជាក់ថាបុរសម្នាក់ និងស្ត្រីម្នាក់ គឺជាប្តីប្រពន្ធស្របច្បាប់។ អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍មានសារៈសំខាន់ជាច្រើនដូចជា៖

- ក្លាយទៅជាប្តីប្រពន្ធស្របតាមផ្លូវច្បាប់ដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួនឡើយ។
- ប្តី ប្រពន្ធមានសិទ្ធិជ្រើសរើសដោយសេរីនូវវិជ្ជាជីវៈ សកម្មភាពនយោបាយ វប្បធម៌ និងសង្គម។
- ប្តី ប្រពន្ធមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ការអាស្រ័យផល ការចាត់ចែងទ្រព្យសម្បត្តិរួម។
- កាន់តែមានសុភមង្គល និងជឿទុកចិត្តគ្នាពេលមានសំបុត្រអាពាហ៍ពិពាហ៍។
- ធ្វើប្លង់កម្មសិទ្ធិទ្រព្យសម្បត្តិរួម។

- ធ្វើសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ។
- ចុះបញ្ជីអត្រានុកុលដ្ឋានកំណើតរបស់កូន។
- ទទួលបានមរតកស្របច្បាប់ ។
- សិទ្ធិទទួលបានអត្តាធិនភាពចំពោះគូស្វាមីអនីតិជនបន្ទាប់ពីចុះសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់។
- ការពារប្រឆាំងនឹងទ្វេពន្ធភាព ការពារការមានប្ដីច្រើន ប្រពន្ធច្រើន។
- មានសិទ្ធិទទួលអាហារកិច្ចនៅពេលលែងលះ ។
- ទ្រព្យសម្បត្តិរួមក្រោយអាពាហ៍ពិពាហ៍ត្រូវចែកគ្នាស្មើនៅពេលលែងលះ។

### ១.៣.៣. សារៈសំខាន់នៃអត្រានុកូលដ្ឋានមរណភាព

លិខិតបញ្ជាក់មរណភាព គឺជាឯកសារអត្តសញ្ញាណផ្លូវការសម្រាប់នៅពេលមាននរណាម្នាក់ស្លាប់។ អត្រានុកូលដ្ឋានមរណភាពមានសារៈសំខាន់ដូចជា៖

- បញ្ជាក់ពីជំងឺតាមរោគវិនិច្ឆ័យ អាចដឹងពីមូលហេតុមរណភាព។
- អាចដឹងពីចំនួនប្រជាជនក្នុងប្រទេស និងអាយុជាមធ្យមនៃមរណភាពបុរស និងស្ត្រី។
- អាចរៀបការថ្មីស្របច្បាប់។
- ទទួលបានកេរមរតកស្របច្បាប់។
- ប្រើប្រាស់ជាមូលដ្ឋានក្នុងកិច្ចការផ្សេងៗ។

## ១.៤. មន្ត្រីមានសមត្ថកិច្ចនៃអត្រានុកូលដ្ឋាន

### ១.៤.១. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ គឺជាមន្ត្រីអត្រានុកុលដ្ឋានថ្នាក់ជាតិ។ ក្នុងករណីដែល អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ អវត្តមាន នោះអគ្គនាយករង ម្នាក់ដែលទទួលសិទ្ធិជាអគ្គនាយកស្ដីទីមានសិទ្ធិអំណាចទទួលខុសត្រូវជាមន្ត្រីអត្រានុកុលដ្ឋានថ្នាក់ជាតិ។[19]

**មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មានសមត្ថកិច្ចដូចខាងក្រោម៖**

- គ្រប់គ្រង និងរក្សាទុកបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលបានអនុវត្តរួច។
- ធានាការអនុវត្តបទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានាស្ដីពីអត្រានុកូលដ្ឋានដែលស្ថិតនៅក្រោមច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកុលដ្ឋាន និងអត្តសញ្ញាណកម្ម។

[19] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៧

- ដាក់ចេញគោលការណ៍ សេចក្តីណែនាំ និងបែបបទ នីតិវិធីស្របតាមការកំណត់ក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។
- ត្រួតពិនិត្យ និងណែនាំទៅដល់មន្ត្រីអត្រានុកូលដ្ឋានគ្រប់ថ្នាក់ រួមទាំងមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស លើការអនុវត្តការងារអត្រានុកូលដ្ឋាន។
- អភិវឌ្ឍផែនការ និងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋាន។
- ជំរុញឱ្យមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត និងមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេសផ្តល់របាយការណ៍អត្រានុកូលដ្ឋាន ឱ្យបានទៀងទាត់ និងត្រឹមត្រូវតាមការកំណត់។
- រាយការណ៍រាល់ករណីរំលោភបទប្បញ្ញត្តិច្បាប់ ដែលប្រព្រឹត្តឡើងដោយមន្ត្រីអត្រានុកូលដ្ឋានជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីចាត់វិធានការតាមច្បាប់។
- ពិនិត្យសម្រេច និងអនុញ្ញាតឱ្យកែតម្រូវទិន្នន័យអត្រានុកូលដ្ឋាន ការឱ្យចុះបញ្ជីអត្រានុកូលដ្ឋានឡើងវិញឱ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។
- ពិនិត្យ និងសម្រេចលើការចុះបញ្ជីអត្រានុកូលដ្ឋាន ក្នុងករណីដែលមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ផ្សេងទៀតមិនអាចសម្រេចបាន។
- ពិនិត្យ និងសម្រេចលើបណ្តឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានគ្រប់លំដាប់ថ្នាក់ រួមទាំងមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជាអំពីការចុះបញ្ជីអត្រានុកូលដ្ឋាន។
- ចេញសេចក្តីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ក្នុងករណីដែលមានការស្នើសុំ។
- ក្នុងករណីដែលចាំបាច់ ស្នើសុំគោលការណ៍ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុង ការបង្កើតការិយាល័យចុះបញ្ជីអត្រានុកូលដ្ឋាននៅក្នុងមូលដ្ឋានសុខាភិបាល ឬកន្លែងផ្សេងទៀត ដែលព្រឹត្តិការណ៍ជីវិតអាចកើតឡើងដោយរៀបចំឱ្យមានបុគ្គលិកអត្រានុកូលដ្ឋាន ឬធ្វើប្រតិភូកម្មភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានទៅដល់មន្ត្រីសុខាភិបាល។
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតដែលកំណត់ដោយអនុក្រឹត្យ។[20]

### ១. ៤.២. មន្ត្រីអត្រានុកូលដ្ឋាន ថ្នាក់រាជធានីខេត្ត

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្តក្នុងដែនសមត្ថកិច្ច

[20] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា12

ដែលខ្លួនគ្រប់គ្រង។ ក្នុងករណីដែលអភិបាលនៃគណៈអភិបាលរាជធានីខេត្ត អវត្តមាន អភិបាលរងរាជធានី ខេត្ត ដែលទទួលសិទ្ធិជាអភិបាលស្ដីទីនៃគណៈអភិបាលរាជធានី ខេត្តមានសិទ្ធិអំណាចក្នុងការទទួលខុសត្រូវជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត និងត្រូវរាយការណ៍ជាផ្លូវការជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។[21]

**មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត មានសមត្ថកិច្ចដូចខាងក្រោម៖**

- ចេញសេចក្ដីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍តាមការស្នើសុំ។
- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋានដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន ដោយយោងតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឬច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។
- តាមដាន ត្រួតពិនិត្យ និងគាំទ្រការអនុវត្តការងាររបស់មន្ត្រីអត្រានុកូលដ្ឋាន ថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានាស្ដីពីអត្រានុកូលដ្ឋាន ដែលស្ថិតនៅក្រោមច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។
- អភិវឌ្ឍផែនការ និងផ្ដល់ការបណ្ដុះបណ្ដាលដល់មន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ជំរុញឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផ្ដល់របាយការណ៍អំពីអត្រានុកូលដ្ឋានឱ្យបានទៀងទាត់ និងត្រឹមត្រូវតាមការកំណត់។
- ពិនិត្យ និងសម្រេចលើការចុះបញ្ជីអត្រានុកូលដ្ឋាន ក្នុងករណីដែលមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ មិនអាចសម្រេចបាន។
- ពិនិត្យ និងសម្រេចលើបណ្ដឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្ដីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសនៅក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ អំពី ការចុះបញ្ជីអត្រានុកូលដ្ឋាន។
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀត ដែលកំណត់ដោយអនុក្រឹត្យ។[22]

### ១.៤.៣. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង។ ក្នុងករណីដែលអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌអវត្តមានអភិបាលរងក្រុង ស្រុក ខណ្ឌ ដែលទទួលសិទ្ធិជាអភិបាលស្ដីទីនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មានសិទ្ធិ អំណាចទទួល

[21] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៨

[22] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា13

ខុសត្រូវជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ និងត្រូវរាយការណ៍ជាផ្លូវការជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត។[23]

**មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ មានសមត្ថកិច្ចដូចខាងក្រោម៖**

- ចេញសេចក្ដីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍តាមការស្នើសុំ។
- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានដោយយោងតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឬច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។
- តាមដាន ត្រួតពិនិត្យ និងគាំទ្រការអនុវត្តការងាររបស់មន្ត្រីអត្រានុកូលដ្ឋាន ថ្នាក់ឃុំ សង្កាត់ ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានា ស្តីពីអត្រានុកូលដ្ឋាន ដែលស្ថិតនៅក្រោមច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។
- គាំទ្រ និងពង្រឹងសមត្ថភាពដល់មន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ជំរុញឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផ្តល់របាយការណ៍អំពីអត្រានុកូលដ្ឋានឱ្យបានទៀងទាត់ និងត្រឹមត្រូវតាមការកំណត់។
- ពិនិត្យ និងសម្រេចលើការចុះបញ្ជីអត្រានុកូលដ្ឋាន ក្នុងករណីមន្ត្រីអត្រានុកូលដ្ឋាន ថ្នាក់ឃុំ សង្កាត់មិនអាចសម្រេចបាន។
- ត្រួតពិនិត្យ និងសម្រេចលើបណ្តឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្ដីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសផ្សេងៗនៅក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ ឬសង្កាត់អំពីការចុះបញ្ជីអត្រានុកូលដ្ឋាន។
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតដែលកំណត់ដោយអនុក្រឹត្យ។[24]

### ១.៤.៤. មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់

មេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង។ ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមាន មេឃុំ ចៅសង្កាត់ ត្រូវប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរជូនអ្នកជំនួយការមេឃុំ ចៅសង្កាត់តាមឋានានុក្រម និងត្រូវរាយការណ៍ជាផ្លូវការ ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ។ ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមានដោយសារមរណភាព ឬដោយការបញ្ឈប់មុខតំណែងក្នុងរយៈពេល

[23] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៩

[24] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា14

អន្តរកាលដែលមិនទាន់មានការតែងតាំងមេឃុំ ចៅសង្កាត់ថ្មី មេឃុំចៅសង្កាត់ស្តីទី គឺជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់។[25]

**មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ មានសមត្ថកិច្ចដូចខាងក្រោម៖**

- ពិនិត្យ និងកត់ត្រាព័ត៌មានចាំបាច់នានាទាក់ទងនឹងកំណើតរស់ មរណភាព និងអាពាហ៍ពិពាហ៍។
- ចេញសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ច្បាប់ដើម និងសេចក្តីចម្លង។
- កែតម្រូវកំហុស នៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានយោងតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឬច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។
- ផ្តល់ការអនុញ្ញាតសម្រាប់ការបូជាសព ឬការបញ្ចុះសព។
- កត់ត្រា កែតម្រូវ ឬធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចជាស្ថាពររបស់តុលាការ ឬទៅតាមការសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋាន ថ្នាក់លើដែលមានអានុភាពអនុវត្ត។
- ផ្តល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់ និងត្រឹមត្រូវទៅតាមការកំណត់។
- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនចំពោះការចុះបញ្ជីអត្រានុកូលដ្ឋាន និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន។
- សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋាន មន្ត្រីសុខាភិបាល មន្ត្រីអប់រំ មន្ត្រីសង្គមកិច្ច និងមន្ត្រីនៃក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀត អំពីការងារអត្រានុកូលដ្ឋានក្នុងករណីដែលចាំបាច់។
- ធ្វើការចុះបញ្ជីអត្រានុកូលដ្ឋានចល័ត នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីសម្រេចឱ្យបាននូវការចុះបញ្ជីអត្រានុកូលដ្ឋានពេញលេញ។
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀត ដែលកំណត់ដោយអនុក្រឹត្យ។[26]

[25] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា១០

[26] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា15

# ជំពូកទី២

# នីតិវិធីនៃការសុំចុះបញ្ជី អត្រានុកូលដ្ឋាន កំណើត អាពាហ៍ពិពាហ៍ និងមរណភាព

# ជំពូកទី២

# នីតិវិធីនៃការសុំចុះបញ្ជីអត្រានុកូលដ្ឋានកំណើត អាពាហ៍ពិពាហ៍ និងមរណភាព

## ២.១. ការសុំចុះបញ្ជីអត្រានុកូលដ្ឋាន និងសៀវភៅអត្រានុកូលដ្ឋាន

ព្រឹត្តិការណ៍ជីវិតដែលត្រូវចុះបញ្ជីអត្រានុកូលដ្ឋានរួមមានបញ្ជីកំណើតរស់ បញ្ជីមរណភាព និងបញ្ជីអាពាហ៍ពិពាហ៍។ ទម្រង់បញ្ជីអត្រានុកូលដ្ឋានអាចរក្សាទុកក្នុងទម្រង់ក្រដាស ឬទម្រង់អេឡិចត្រូនិក ទម្រង់ និងព័ត៌មានដែលមាននៅក្នុងបញ្ជីអត្រានុកូលដ្ឋាន និងទម្រង់ប្រើប្រាស់ដើម្បីជូនដំណឹង រាយការណ៍ និងចុះបញ្ជីព្រឹត្តិការណ៍ជីវិតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលើកលែងតែមានបទប្បញ្ញត្តិដោយឡែកបានចែង។[27] រាល់ការសុំចុះសៀវភៅអនុត្រានុកូលដ្ឋាន កំណើត និងមរណភាព អ្នករាយការណ៍ ឬសាក្សីត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ចំពោះការសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍សាមីខ្លួន និងសាក្សីត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។[28]

### ២.១.១. ឯកសារនៃការចុះបញ្ជីអត្រានុកូលដ្ឋាន

ក្នុងឃុំ ឬសង្កាត់នីមួយៗត្រូវមានសៀវភៅអត្រានុកូលដ្ឋានសម្រាប់កត់ត្រាអំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព បញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និងបញ្ជាក់មរណភាព។ សៀវភៅនេះត្រូវធ្វើជា ០២ច្បាប់ដូចគ្នាតាមប្រភេទនីមួយៗតាមគំរូដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ សៀវភៅនេះត្រូវចុះចំនួនសន្លឹក និងចុះលេខរៀងសន្លឹកពីសន្លឹកទី ០១ ដល់សន្លឹកចុងក្រោយ។ សន្លឹកទី ០១ និងសន្លឹកចុងក្រោយត្រូវសរសេរជាអក្សរ និងត្រូវចុះហត្ថលេខាពេញដោយអភិបាលស្រុក ឬអភិបាលខណ្ឌ។ ចំណែកសន្លឹកទី ០២ និងសន្លឹកដទៃផ្សេងទៀត ដែលអាចចុះហត្ថលេខាសង្ខេប និងបោះត្រារបស់អភិបាលស្រុក ឬអភិបាលខណ្ឌគ្រប់សន្លឹក។[29] សៀវភៅអត្រានុកូលដ្ឋានទាំងអស់ មិនត្រូវឱ្យមាន កោស ឆូត លុប សរសេរជ្រៀតថែមឡើយ។ បើមានកោស ឆូត លុបត្រូវទុកពាក្យទាំងនោះឱ្យនៅមើលបាន ហើយសរសេរទឹកខ្មៅពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងថាយល់ព្រមលុបប៉ុន្មានពាក្យ និងយល់ព្រមថែមប៉ុន្មានពាក្យ ទើបមន្ត្រីអត្រានុកូលដ្ឋាន អ្នករាយការណ៍

[27] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៥-មាត្រា៦

[28] អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២000, មាត្រា៤

[29] អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២000, មាត្រា១២

ឬសាក្សី ឬសាមីខ្លួនចុះហត្ថលេខា ឬផ្តិតមេដៃស្តាំទាំងអស់គ្នា។ ចំពោះសន្លឹកណាដែលសរសេរខុសត្រូវរក្សាទុកជាឯកសារមិនឱ្យហែកចោលឡើយ ។[30]

### ២.១.១.១. ឯកសារនៃការចុះបញ្ជីអត្រានុកូលដ្ឋានកំណើត

#### ក. សញ្ញាណនៃការចុះបញ្ជីអត្រានុកូលដ្ឋានកំណើត

រាល់កំណើតរស់ដែលបានកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរាយការណ៍ និងចុះបញ្ជីតាមកំណត់នៃច្បាប់ ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។[31] អ្នករាយការណ៍ត្រូវភ្ជាប់ឯកសារដែលបញ្ជាក់អំពីកំណើតរស់ជាមួយនឹងពាក្យស្នើសុំចុះបញ្ជីកំណើតរស់។ ប្រសិនបើអ្នករាយការណ៍មិនមានឯកសារបញ្ជាក់អំពីកំណើតទេ អ្នករាយការណ៍ត្រូវភ្ជាប់ឯកសារផ្សេងៗទៀតដែលអាចបញ្ជាក់អំពីកំណើតរស់របស់ទារកនោះ។ អ្នករាយការណ៍ក៏ត្រូវភ្ជាប់ផងដែរនូវឯកសារដែលអាចបញ្ជាក់អត្តសញ្ញាណ របស់ឪពុកម្តាយរបស់ទារកជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់។ ឯកសារផ្សេងៗទៀតដែលអាចបញ្ជាក់អំពីកំណើតរស់របស់ទារកដែលអាចបញ្ជាក់អត្តសញ្ញាណរបស់ឪពុកម្តាយរបស់ទារកនោះ ត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[32]

ត្រូវទទួលបានសញ្ជាតិខ្មែរពីកំណើតទោះបីជាកើតទីណាក៏ដោយចំពោះកូនដែលបានកើតពីឪពុក ឬម្តាយមានសញ្ជាតិខ្មែរ ឬកូនដែលឪពុកម្តាយមិនទទួលស្គាល់កាលបើតុលាការបានចេញសាលក្រមថាកូននោះពិតជាកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ។ ត្រូវទទួលបានសញ្ជាតិខ្មែរពីកំណើតដោយកើតព្រោះនៅក្នុងប្រទេសកម្ពុជា ចំពោះកូនដែលកើតពីឪពុក និងម្តាយដែលជាជនបរទេសដែលកើត និងរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា កូនដែលកើតពីឪពុកម្តាយមិនស្គាល់ និងកូនទើបនឹងកើតដែលគេរើសបាននៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវចាត់ទុកថាកើតនៅព្រះរាជាណាចក្រកម្ពុជាដែរ។[33]

#### ខ. ការចុះបញ្ជីកំណើតរស់សម្រាប់ទារកដែលគេបោះបង់

ប្រសិនបើជនណាម្នាក់ដែលរើសបានទារកដែលគេបោះបង់ ជននោះត្រូវផ្តល់ព័ត៌មានអំពីព្រឹត្តិការណ៍នោះទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ដែលទារកត្រូវបានរើសបានដោយគ្មានការយឺតយ៉ាវ។ ជនដែលរើស

---

[30] អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា១៣

[31] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា១៧

[32] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា២៤

[33] ច្បាប់ ស្តីពីសញ្ជាតិ, ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨, ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨, មាត្រា៩

បានទារកនៅរស់នោះត្រូវផ្តល់កាលបរិច្ឆេទ និងទីកន្លែងដែលខ្លួនរើសបានទារក ភេទរបស់ទារក ការប៉ាន់ស្មានអំពីថ្ងៃខែឆ្នាំកំណើតរបស់ទារក ឈ្មោះ និងលំនៅឋានរបស់ទារកនោះ។ ក្រោយពេលដែលទទួលបានព័ត៌មាន មន្ត្រីអត្រានុកូលដ្ឋានត្រូវកត់ព័ត៌មាន និងចុះបញ្ជីកំណើតរស់របស់ទារកនោះដោយកំណត់ឈ្មោះទារក ទោះបីគ្មានអ្នករាយការណ៍ដាក់ពាក្យសុំក៏ដោយ។ ក្នុងករណីដែលចាំបាច់ ប្រសិនបើការប៉ាន់ស្មានអំពីថ្ងៃខែឆ្នាំកំណើតរបស់ទារកនោះមិនអាចធ្វើទៅបាន មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះជាមួយមន្ត្រីសុខាភិបាលដើម្បីកំណត់ថ្ងៃ ខែ ឆ្នាំកំណើតរបស់ទារកនោះ។ ប្រសិនបើទីកន្លែងកំណើតរបស់ទារកនោះមិនច្បាស់លាស់ ទីកន្លែងដែលរើសបានទារកនោះត្រូវសន្មតថាជាទីកន្លែងកំណើតរបស់ទារក។ ក្រោយពីពេលទារកនោះត្រូវបានចុះបញ្ជីរួចរាល់ហើយ មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃទីកន្លែងដែលរើសបានទារកនោះត្រូវបញ្ជូនទារកនោះទៅកាន់មជ្ឈមណ្ឌលសាធារណៈសម្រាប់សុខមាលភាពកុមារដោយភ្ជាប់ទៅជាមួយសំបុត្រកំណើតដើម្បីចាត់ការតាមនីតិវិធី។ ចំពោះអាណាព្យាបាលសម្រាប់អនីតិជនចំពោះទារកដែលត្រូវបានរើសបានអាចដាក់ពាក្យសុំទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចដើម្បីកែប្រែ ឬបំពេញបន្ថែមនូវព័ត៌មានរបស់ទារកទៅក្នុងបញ្ជីកំណើតរបស់ទារកនោះ។ សម្រាប់ទារកដែលបានកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានសន្មតថាមានសញ្ជាតិខ្មែរពីកំណើត។[34]

**គ. ការសុំចុះបញ្ជីកំណើតរស់សម្រាប់កុមារក្នុងមជ្ឈមណ្ឌលសាធារណៈ និងទារកកើតពីស្ត្រីនៅឃុំនៅពន្ធនាគារ**

ការចុះបញ្ជីកំណើតរស់ សម្រាប់កុមារនៅក្នុងមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខមាលភាពកុមារត្រូវធានាថា កុមារទាំងអស់ដែលកំពុងរស់នៅក្នុងមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខមាលភាពកុមារនោះត្រូវបានចុះបញ្ជីកំណើតរស់។ ប្រធានមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខាមាលភាពកុមារ ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាអ្នករាយការណ៍។[35] ប្រធានពន្ធនាគារ ឬប្រធានមណ្ឌលយុវនីតិសម្បទាត្រូវធានាថាទារកទាំងអស់ដែលបានកើតពីស្ត្រីជាជនជាប់ឃុំក្នុងពន្ធនាគារ ឬមណ្ឌលយុវនីតិសម្បទា ត្រូវបានចុះបញ្ជីកំណើត។ ប្រធានពន្ធនាគារ ឬប្រធានមណ្ឌលនីតិសម្បទាត្រូវមានតួនាទីជាអ្នករាយការណ៍។[36]

[34] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៣០

[35] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៣២

[36] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា ៣៤

### ឃ. ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានកំណើត

បើមានទារកកើត ឪពុក ឬម្ដាយមានកាតព្វកិច្ចត្រូវទៅរាយការណ៍ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋាន នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំ សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់ឪពុកម្ដាយ របស់ទារកនោះ មិនឱ្យហួសរយៈពេល ៣០ថ្ងៃ។ ករណីឪពុក ឬម្ដាយមានធុរៈចាំបាច់ពុំអាចទៅសុំចុះសៀវភៅអត្រានុកូលដ្ឋាន កំណើតបានអាចពឹងពាក់ញាតិជានីតិជនដែលរស់នៅជាមួយឪពុកម្ដាយ ឱ្យទៅសុំចុះសៀវភៅអត្រានុកូលដ្ឋាន កំណើត។ ការដាក់ឈ្មោះ គឺត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីឪពុកម្ដាយទារកនោះ និងត្រូវយក សំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍របស់ឪពុកម្ដាយរបស់ទារក ឬឯកសារភស្តុតាងផ្សេងៗ ដែលមានបញ្ជាក់ភាពជាប្ដីប្រពន្ធទៅជាមួយផង។ ទារកដែលបានចុះសៀវភៅអត្រានុកូលដ្ឋានកំណើតក្នុងរយៈ ពេលកំណត់ ៣០ថ្ងៃ មន្ត្រីអត្រានុកូលដ្ឋាននឹងផ្ដល់នូវសំបុត្រកំណើតច្បាប់ដើមមួយសន្លឹកដោយឥតគិតថ្លៃ។

ចំពោះទារកដែលបានកើតហើយទុកឱ្យហួសក្នុងរយៈពេលកំណត់ ៣០ថ្ងៃ ហើយពុំទាន់មានសំបុត្រ កំណើតប្រើប្រាស់ទេសាមីខ្លួន ឬឪពុកម្ដាយ ឬអាណាព្យាបាល ត្រូវប្ដឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់ កំណើតនៅសាលាឃុំ សង្កាត់ដែលសាមីខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្នដែលនាំទៅជាមួយនូវសាក្សីចំនួន ០២ រូបជានីតិជន ហើយត្រូវមានទីលំនៅពិតប្រាកដមកបញ្ជាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

បើមានជនណាម្នាក់រើសបានទារកដែលគេបោះបង់ចោល ត្រូវយកទៅប្រគល់ឱ្យមន្ត្រីអត្រានុកូលដ្ឋាន ក្នុងឃុំ ឬសង្កាត់នៃទីកន្លែងដែលរើសបានទារកនោះ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើកំណត់ហេតុ និងចុះសៀវភៅ អត្រានុកូលដ្ឋានកំណើតដោយរកឈ្មោះដាក់ឱ្យទារកនោះ។ ក្នុងករណីចាំបាច់ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះ យោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃខែឆ្នាំកំណើតទារកដែលបានរើសបាននោះដោយស្មាន និង ឈ្មោះឪពុកម្ដាយដាក់ថាមិនស្គាល់។

ចំពោះទារកដែលកើតពីឪពុកម្ដាយដែលគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ក៏ត្រូវចុះក្នុងសៀវភៅ អត្រានុកូលដ្ឋានកំណើតដែរ។ នៅពេលដែលធ្វើសំបុត្រកំណើត ប្រសិនបើឪពុក និងម្ដាយដែលគ្មានចំណង អាពាហ៍ពិពាហ៍នោះបានឆ្លើយទទួលស្គាល់ដោយជាក់លាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ថាទារកដែលកើត មកជាកូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឪពុក និងម្ដាយនោះជាឪពុកម្ដាយរបស់កូននោះ។ ក្នុង ករណីមានតែឪពុក ឬមានតែម្ដាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកជាកូនដែលបានទទួល ស្គាល់តែម្នាក់ឯងប៉ុណ្ណោះ។[37]

[37] កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន, ទំព័រទី៤៨-៤៩

### ២.១.១.២. ឯកសារនៃការចុះបញ្ជីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍

#### ក. លក្ខខណ្ឌដែលអាចរៀបអាពាហ៍ពិពាហ៍បាន

**ការព្រមព្រៀង** អាពាហ៍ពិពាហ៍ គឺការព្រមព្រៀងដែលកើតចេញពីឆន្ទៈពិតប្រាកដរបស់បុរស និងនារី ដែលគ្មានអ្នកណាមួយអាចបង្ខំឱ្យបុគ្គលម្នាក់ឱ្យរៀប ឬរារាំងមិនឱ្យរៀបអាពាហ៍ពិពាហ៍បានឡើយ។

**អាយុ** អាចរៀបអាពាហ៍ពិពាហ៍បានបុរស និងនារីត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើង។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បានដោយត្រូវទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ។

**នៅលីវ** បុគ្គលដែលមានសហព័ទ្ធរួចហើយពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ ប្រសិនបើភាគីណាមួយកំពុងមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ត្រូវតែបញ្ចប់ចំណងអាពាហ៍ពិពាហ៍នោះជាមុនសិនតាមរយៈសេចក្តីសម្រេចរបស់តុលាការទើបអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន។ ក្នុងករណីដែលមានសហព័ទ្ធរួចហើយសហព័ទ្ធណាមួយបានបាត់ខ្លួនកន្លងហួសពីមួយឆ្នាំគិតពីថ្ងៃដែលបាត់ខ្លួននោះមកដោយពុំមានដំណឹងអ្វីសោះហើយក៏គ្មានអ្នកណាដឹងថាជននោះស្លាប់ ឬរស់ សហព័ទ្ធម្នាក់ទៀតអាចនឹងរៀបអាពាហ៍ពិពាហ៍ទៀតបានបើផុតរយៈពេល ១៥ថ្ងៃគិតពីថ្ងៃដែលប្រកាសសាលក្រមដែលបញ្ជាក់ថាជននោះបានបាត់ខ្លួនពិតមែន។

**ភេទ** អាចរៀបអាពាហ៍ពិពាហ៍បានស្របច្បាប់ភាគីចាំបាច់ត្រូវតែមានភេទផ្ទុយគ្នា គឺបុរស និងនារី។

#### ខ. លក្ខខណ្ឌដែលមិនអាចរៀបអាពាហ៍ពិពាហ៍បាន

លក្ខខណ្ឌដែលបុរស និងនារីមិនអាចរៀបអាពាហ៍ពិពាហ៍បានមានដូចជាៈ

- ជនវិកលចរិក មិនដឹងខុសត្រូវ។
- ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត ទាំងញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិត(ឪពុកម្តាយ កូន និងចៅបង្កើត ឬកូន និងចៅសុំស្របច្បាប់) ទោះបីទំនាក់ទំនងញាតិត្រូវបានបញ្ចប់ក៏ដោយក៏មិនអាចរៀបអាពាហ៍ពិពាហ៍បានដែរ។
- ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធខ្សែផ្ទាល់ទោះបីជាក្រោយពេលដែលបានបញ្ចប់ទំនាក់ទំនងញាតិពន្ធ ការកាត់កាលនៃការសុំកូនពេញលេញក៏ដោយ ក៏មិនអាចរៀបអាពាហ៍ពិពាហ៍បានដែរ។ អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយរវាងសាខាញាតិពន្ធនៅក្នុងបីថ្នាក់ ទោះបីជាទំនាក់ទំនង

ញាតិពន្ធត្រូវបានបញ្ចប់ក៏ដោយ។ ប៉ុន្តែប្រសិនបើសហព័ទ្ធណាម្ខាងបានទទួលមរណភាព សហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលដែលធ្លាប់ជាសាខាញាតិពន្ធនៅក្នុងបីថ្នាក់បាន។

**ឧទាហរណ៍** មិនអាចរៀបអាពាហ៍ពិពាហ៍បានទេចំពោះ ឪពុកម្ដាយ និងកូន បងប្អូនបង្កើត មាមីង និងក្មួយ មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ឪពុកម្ដាយ និងកូនប្រសារ បងប្អូនថ្លៃ មាមីង និងក្មួយប្រសារ អាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានតាមផ្លូវច្បាប់ ប្រសិនបើសហព័ទ្ធណាមួយស្លាប់។

**គ. ការចុះបញ្ជីអាពាហ៍ពិពាហ៍**

ដើម្បីទទួលបានសំបុត្រអាពាហ៍ពិពាហ៍មួយស្របច្បាប់ត្រូវធ្វើដូចជា៖

- អាពាហ៍ពិពាហ៍ត្រូវចាត់ទុកថាស្របច្បាប់ លុះត្រាណាតែបុរស និងនារីបានចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ដែលបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះ។
- ព័ត៌មាន ឬចំណុចដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ ត្រូវបញ្ចូលទៅក្នុងបញ្ជីអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន និងចុះហត្ថលេខា ឬផ្តិតស្នាមមេដៃដោយបុគ្គល ដែលមានបំណងធ្វើជាសហព័ទ្ធ និងដោយមានសាក្សីចំនួន ០២រូបជានីតិជន។
- ក្រោយពេលដែលចុះបញ្ជីអាពាហ៍ពិពាហ៍រួចរាល់ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវចេញសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមួយច្បាប់ជូនប្តីប្រពន្ធនោះដោយឥតគិតថ្លៃ។[38]

### ២.១.១.៣. ឯកសារនៃការចុះបញ្ជីអត្រានុកូលដ្ឋានមរណភាព

**ក. ជំហានសំខាន់ៗនៃការចុះបញ្ជីអត្រានុកូលដ្ឋានមរណភាព**

ជំហានសំខាន់ៗនៃការចុះបញ្ជីអត្រានុកូលដ្ឋានមរណភាពមានដូចខាងក្រោម៖

- ពិនិត្យឯកសារដែលអ្នកសុំចុះបញ្ជីនាំមកជាមួយ លិខិតជូនដំណឹងមរណភាព និងសៀវភៅគ្រួសារ។
- សរសេរចូលក្នុងបញ្ជីឈ្មោះនៃសៀវភៅអត្រានុកូលដ្ឋានទាំងពីរក្បាល។
- ឱ្យអ្នកដែលសុំចុះបញ្ជី ឬអ្នករាយការណ៍ត្រូវពិនិត្យទិន្នន័យដែលបានសរសេរចូលឱ្យបានច្បាស់លាស់ បើសិនជាគាត់ចេះអក្សរ ឬអានឱ្យគាត់ស្តាប់បើសិនគាត់មិនចេះអក្សរមុននឹងអនុញ្ញាតឱ្យអ្នកសុំចុះបញ្ជីផ្តិតស្នាមមេដៃនៅលើបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋាន និងអនុញ្ញាតឱ្យអ្នកសុំចុះបញ្ជីផ្តិតមេដៃស្តាំត្រង់ពាក្យអ្នករាយការណ៍។

[38] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៧០-៧១

- ស្រង់ទិន្នន័យពីក្នុងសៀវភៅសរសេរចូលទៅក្នុងសំបុត្រ។
- ចុះហត្ថលេខា បោះត្រា និងផ្តល់សំបុត្រទៅឱ្យអ្នកស្នើសុំចុះបញ្ជី ព្រមទាំងបញ្ជាក់ប្រាប់គាត់ថាសូមរក្សាទុកសំបុត្រនេះ ឱ្យបានល្អព្រោះច្បាប់ដើមមានតែមួយ និងចេញតែម្តងគត់ក្នុងមួយជីវិត។
- ករណីចង់យកទៅប្រើប្រាស់ដោយប្រការណាមួយ ត្រូវសុំចម្លងនៅឃុំ សង្កាត់ (ក្នុងឆ្នាំ) និងចម្លងនៅសាលាក្រុង ស្រុក ខណ្ឌ ឬក្រសួងមហាផ្ទៃ (ឆ្លងឆ្នាំ)។[39]

## ខ. ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព

នៅពេលមានអ្នកស្លាប់ភ្លាមក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ចនៅក្នុងក្រសួងស្ថាប័នអង្គភាពរបស់អ្នកស្លាប់ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃទីកន្លែងដែលរស់នៅជាប់លាប់របស់មរណជនឱ្យទាន់រយៈពេល ១៥ថ្ងៃក្រោយពីថ្ងៃដែលទទួលមរណភាព។ ការចុះសៀវភៅអត្រានុកូលដ្ឋាន ត្រូវផ្តល់សំបុត្រមរណភាពច្បាប់ដើមមួយសន្លឹកដោយឥតគិតថ្លៃជូនចំពោះក្រុមគ្រួសារ ញាតិរបស់មរណជនដែលបានមករាយការណ៍ស្នើសុំចុះសៀវភៅបញ្ជីអត្រានុកូលដ្ឋានមរណភាពឱ្យមរណជនក្នុងនៅរយៈពេលកំណត់ ១៥ថ្ងៃ។

**ករណីមានអ្នកស្លាប់ទុកឱ្យហួសរយៈពេលដែលកំណត់ដោយច្បាប់ ត្រូវអនុវត្តដូចខាងក្រោម៖**

- បើសិនមានអ្នកស្លាប់ហើយទុកហួសរយៈពេល ១៥ថ្ងៃនៅក្នុងឆ្នាំពុំបានទៅរាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ក្រុមគ្រួសារនៃអ្នកស្លាប់ត្រូវប្តឹងសុំសំបុត្រមរណភាពពីមេឃុំ ចៅសង្កាត់សាមីនៃលំនៅឋានពិតប្រាកដរបស់អ្នកស្លាប់។
- បើមានអ្នកស្លាប់ទុកឱ្យហួសឆ្នាំ ហើយពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេនោះក្រុមគ្រួសារនៃអ្នកស្លាប់ត្រូវប្តឹងសុំសាលក្រមពីសាលាដំបូងរាជធានី ខេត្តសាមី រួចយកសាលក្រមនោះមកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃអ្នកស្លាប់ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន។ ប្រសិនបើមានសាលក្រមបញ្ជាក់ពីមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះបញ្ជីអត្រានុកូលដ្ឋានមរណភាព។[40]
- រាល់មរណភាពដែលកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវរាយការណ៍ និងចុះបញ្ជីមរណភាពតាមប្បញ្ញត្តិច្បាប់ ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។[41]

---

[39] កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន, ទំព័រ១៣០

[40] កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន, ទំព័រ១២៥

[41] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៤១

**អ្នករាយការណ៍ត្រូវដាក់ពាក្យដើម្បីសុំចុះបញ្ជីមរណភាពនៅការិយាល័យអត្រានុកូលដ្ឋានណាមួយដូចខាងក្រោម៖**

- ឃុំ សង្កាត់ដែលព្រឹត្តិការណ៍មរណភាពបានកើតឡើង។
- ឃុំ សង្កាត់ដែលមរណជនស្នាក់នៅ។
- កន្លែងផ្សេងទៀតតាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។[42]

**គ. លិខិតស្នាមដែលទាក់ទងនឹងសាកសព**

លិខិតស្នាមផ្សេងៗដែលទាក់ទងនឹងសាកសពមានដូចជា៖

- លិខិតជូនដំណឹងមរណភាព។
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ បើស្លាប់នៅក្នុងមន្ទីរពេទ្យ។
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើស្លាប់ដោយរោគឆ្លង។
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ប្រសិនបើករណីស្លាប់ទាក់ទងឃាតកម្ម ឧក្រិដ្ឋកម្ម។
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិដែលអ្នកស្លាប់រស់នៅមុនពេលស្លាប់ បើស្លាប់នៅនឹងផ្ទះក្នុងភូមិរបស់សព។
- លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់មួយផ្សេងទៀត ករណីអ្នកស្លាប់បានស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ។
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ករណីអ្នកទោសស្លាប់ក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ។
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាមក្រសួង ស្ថាប័ន ឬអង្គភាព ប្រសិនបើស្លាប់នៅក្នុងក្រសួង ស្ថាប័ន ឬអង្គភាព។
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកស្លាប់។
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ប្រសិនបើសម្រាប់ជនបរទេស និងជនអន្តោប្រវេសន៍ស្របច្បាប់ត្រូវមានឯកសារបន្ថែមទៀត។

[42] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៤៣

- លិខិតឆ្លងដែនរបស់អ្នកស្លាប់ដែលនៅមានសុពលភាព។
- ទិដ្ឋាការ ឬប័ណ្ណស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលនៅមានសុពលភាព។
- ករណីឯកសារណាមួយខាងលើនេះបានបាត់បង់ត្រូវមានលិខិតស្នាមនានាដែលបញ្ជាក់ពីអត្តសញ្ញាណទាក់ទងនឹងអ្នកស្លាប់។[43]

## ២.១.២. ការដាក់ពាក្យសុំចុះបញ្ជីអត្រានុកូលដ្ឋាន

### ២.១.២.១. ការដាក់ពាក្យសុំចុះបញ្ជី និងបញ្ជាក់អត្រានុកូលដ្ឋានកំណើត

#### ក. ការដាក់ពាក្យសុំចុះបញ្ជី

បើមានទារកកើត ឪពុក ឬម្តាយមានកាតព្វកិច្ចត្រូវទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៅសាលាឃុំ ឬសង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុកម្តាយទារកនោះមិនឱ្យហួស ៣០ថ្ងៃដោយបញ្ជាក់ឱ្យបានច្បាស់ថា ឪពុក និងម្តាយនៃទារកនោះមានខាន់ស្លា ឬឥតខាន់ស្លា។ បើមានខាន់ស្លាត្រូវបង្ហាញសំបុត្រអាពាហ៍ពិពាហ៍ពិពាហ៍ របស់ឪពុក និងម្តាយរបស់ទារកនោះ។

បើឪពុកម្តាយមានធុរៈទៅមិនបាន ត្រូវពឹងពាក់អ្នកជាសាច់ញាតិសន្តាន ឬអ្នកនៅជិតខាងដែលបានឃើញ និងដឹងឮផ្ទាល់ពីទារកនោះកើតឱ្យទៅចុះសៀវភៅកំណើតឱ្យបានទាន់ពេលកំណត់ ដោយយកសំបុត្រអាពាហ៍ពិពាហ៍ ឪពុក និងម្តាយរបស់ទារកនោះជាប់ទៅជាមួយផង។[44]

អ្នករាយការណ៍ អាចដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ជាលាយលក្ខណ៍អក្សរ ដោយផ្ទាល់មាត់ ឬតាមទម្រង់អេឡិកត្រូនិក។ ក្នុងពាក្យសុំចុះបញ្ជីកំណើតរស់អ្នករាយការណ៍ត្រូវបំពេញពាក្យសុំនូវចំណុចខាងក្រោម៖

- ឈ្មោះរបស់ទារក។
- ភេទរបស់ទារក។
- ថ្ងៃ ខែ ឆ្នាំកំណើត ម៉ោង និងទីកន្លែងទារកកើតរស់។
- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល សញ្ជាតិ និងលំនៅឋានរបស់ឪពុកម្តាយរបស់ទារក។
- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល និងអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកដែលរាយការណ៍ក្នុងករណីអ្នករាយកាណ៍មិនមែនជាម្តាយ ឬឪពុក។

[43] កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន, ទំព័រ១៣២

[44] អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា១៧

- ថ្ងៃ ខែ ឆ្នាំ ដែលពាក្យសុំត្រូវបានធ្វើឡើង។
- ចំណុចផ្សេងទៀត ដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- ទម្រង់ និងបែបបទនៃពាក្យសុំត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[45]

អ្នករាយការណ៍ត្រូវភ្ជាប់ឯកសារបញ្ជាក់អំពីកំណើតរស់ (ការជូនដំណឹងអំពីកំណើតរស់ដែលកើតនៅក្នុងមូលដ្ឋានសុខាភិបាល) ជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់។ ប្រសិនបើអ្នករាយការណ៍មិនមានឯកសារបញ្ជាក់អំពីកំណើតរស់នោះទេ អ្នករាយការណ៍ត្រូវភ្ជាប់នូវឯកសារផ្សេងទៀតដែលអាចបញ្ជាក់អំពីកំណើតរស់របស់ទារក។ អ្នករាយការណ៍ក៏ត្រូវភ្ជាប់ផងដែរនូវឯកសារដែលអាចបញ្ជាក់អត្តសញ្ញាណរបស់ឪពុកម្ដាយរបស់ទារកជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់។ ឯកសារផ្សេងទៀតដែលអាចបញ្ជាក់អំពីកំណើតរស់របស់ទារក និងឯកសារដែលអាចបញ្ជាក់អត្តសញ្ញាណរបស់ឪពុកម្ដាយរបស់ទារក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[46]

**ឃ. ការបញ្ជាក់អត្រានុកូលដ្ឋានកំណើត**

ពលរដ្ឋខ្មែរដែលបានកើតនៅមុនពេលមានអនុក្រឹត្យ ស្ដីពីអត្រានុកូលដ្ឋានចូលជាធរមាន ហើយគ្មានសំបុត្រកំណើតប្រើប្រាស់ អាចសុំចុះសៀវភៅបញ្ជាក់សំបុត្រកំណើតបានតាមគំរូណែនាំថ្មី នៅសាលាឃុំ ឬសង្កាត់ដែលខ្លួនបានរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូបជានីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបានដែលបានស្គាល់ច្បាស់ពីប្រវត្តិអ្នកត្រូវសុំធ្វើសំបុត្របញ្ជាក់កំណើត និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយ នៅពេលដែលសាមីខ្លួនកើតនាំមកបញ្ជាក់ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬទទួលសោធននិវត្តន៍ត្រូវយកឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្ដីបញ្ជាក់ពីស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះនៅក្នុងសៀវភៅបញ្ជាក់កំណើតមិនត្រូវឱ្យខុសពី ថ្ងៃ ខែ ឆ្នាំកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬសោធននិវត្តន៍ជាផ្លូវការឡើយ ។[47]

---

[45] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា២៣

[46] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា២៤

[47] អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា៤៣

ពេលដែលមានអ្នកមកសុំចុះសៀវភៅកំណើត មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់កំណើតរួច ត្រូវប្រគល់ឱ្យសាមីខ្លួន ឬក្រុមគ្រួសារនូវសំបុត្របញ្ជាក់កំណើតច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួនដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ។[48]

### ២.១.២.២. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងបញ្ជាក់សំបុត្រអាពាហ៍ពិពាហ៍

#### ក. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

ដើម្បីទទួលបានអាពាហ៍ពិពាហ៍មួយស្របច្បាប់ត្រូវធ្វើដូចជា៖

- បុរស និងនារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលបុរស ឬនារីនោះរស់នៅ។
- បុរស និងនារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាន (ទីកន្លែងដាក់ពាក្យអាពាហ៍ពិពាហ៍)។
- ទម្រង់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- ពាក្យសុំរៀបអាពាហ៍ពិពាហ៍ត្រូវភ្ជាប់នូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណ និងឯកសារផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- ប្រសិនបើបុរស ឬនារីមិនទាន់ដល់នីតិភាព ប៉ុន្តែមានអាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍ ដោយអនុលោមទៅតាមមាត្រា៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណី អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់បុរស ឬនារីនោះត្រូវផ្តល់ការយល់ព្រមនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឬជាលាយលក្ខណ៍អក្សរ។[49]
- មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យ និងផ្ទៀងផ្ទាត់ពាក្យសុំ និងឯកសារភ្ជាប់ដោយអនុលោមតាមមាត្រា ៩៥៦ (ការទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណី។[50]
- ការសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់ឯបរទេសត្រូវប្រព្រឹត្តទៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសដែលគូភាគីមានទីលំនៅ។

---

[48] អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា៤៤

[49] ក្រមរដ្ឋប្បវេណី, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៤៨

[50] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៦៧-៦៨

- ក្នុងករណីដែលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ និងអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសបានប្រព្រឹត្តទៅត្រឹមត្រូវតាមទម្រង់នៃអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងច្បាប់នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះត្រូវទទួលស្គាល់យកជាការបាននៅប្រទេសកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះមិនផ្ទុយនឹងបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
- សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍នោះ ត្រូវយកមកចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍នៃស្ថានទូត ឬស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសកម្ពុជាប្រចាំប្រទេសនៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ឬបើប្តីប្រពន្ធមកតាំងលំនៅ នៅព្រះរាជាណាចក្រកម្ពុជាត្រូវយកមកចុះសៀវភៅអាពាហ៍ពិពាហ៍នៅសាលាឃុំ ឬសង្កាត់ដែលខ្លួនបានរស់នៅ។ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល ឬមន្ត្រីអត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពីសៀវភៅនូវសំបុត្រពាហ៍ពិពាហ៍ថ្មីឱ្យទៅជននោះយកទៅប្រើប្រាស់។[51]

### ខ. ការបញ្ជាក់សំបុត្រអាពាហ៍ពិពាហ៍

ពលរដ្ឋខ្មែរដែលបានគ្នាជាប្តី ឬប្រពន្ធពិតប្រាកដនៅមុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានចូលជាធរមានហើយគ្មានសំបុត្រអាពាហ៍ពិពាហ៍ប្រើប្រាស់ទេ សាមីខ្លួនប្តី និងប្រពន្ធអាចមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាម គំរូណែនាំថ្មីនៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូប ជានីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបានដែលបានដឹងឮផ្ទាល់ពីសាមីខ្លួនប្តី ប្រពន្ធនោះ និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយគ្នា នាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

នៅពេលសាមីខ្លួនប្តី និងប្រពន្ធមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួន ប្តី និងប្រពន្ធនូវសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានចុះហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់។[52]

[51] អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា៣២

[52] អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា៤៥-៤៦

### ២.១.២.៣. ការដាក់ពាក្យចុះបញ្ជី និងបញ្ជាក់អត្រានុកូលដ្ឋានមរណភាព

#### ក.ការដាក់ពាក្យសុំចុះបញ្ជីមរណភាព

ពេលមានអ្នកស្លាប់ភ្លាមៗ ក្រុមគ្រួសារ ឬញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកដែលមានភារកិច្ចនៅក្រសួងស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬសង្កាត់នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់។[53] បន្ទាប់មកមន្ត្រីអត្រានុកូលដ្ឋាននឹងធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសព ចុះបញ្ជីមរណភាពក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាពតាមការស្នើសុំរបស់អ្នកដែលបានរាយការណ៍។ អ្នករាយការណ៍អាចដាក់ពាក្យសុំចុះបញ្ជីមរណភាពជាលាយលក្ខណ៍អក្សរ ដោយផ្ទាល់មាត់ ឬតាមទម្រង់អេឡិចត្រូនិក។ ក្នុងពាក្យសុំចុះបញ្ជីមរណភាព អ្នករាយការណ៍ត្រូវបំពេញនូវចំណុចខាងក្រោមនេះ៖

- ឈ្មោះរបស់មរណជន។
- ភេទរបស់មរណជន។
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់មរណជន។
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលមរណជនទទួលមរណភាព។
- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានបច្ចុប្បន្នរបស់អ្នករាយការណ៍ ព្រមទាំងទំនាក់ទំនងរវាងអ្នករាយការណ៍ និងមរណជន។
- ថ្ងៃ ខែ ឆ្នាំ ដែលពាក្យសុំត្រូវបានធ្វើឡើង។
- ចំណុចផ្សេងទៀតតាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- ទម្រង់ និងបែបបទនៃពាក្យសុំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[54]

#### ខ. ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីមរណភាព

អ្នករាយការណ៍ត្រូវភ្ជាប់ឯកសារបញ្ជាក់អំពីមរណភាព (ការជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្នុងមូលដ្ឋាន សុខាភិបាល) ឬ(ការជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល) ឬ (ការជូនដំណឹងអំពីមរណភាពបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិ ឬគ្រោះអាសន្នទ្រង់ទ្រាយធំ) ជាមួយ

[53] អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា៤៨

[54] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៥២

នឹងពាក្យសុំចុះបញ្ជីមរណភាព។ អ្នករាយការណ៍ក៏ត្រូវភ្ជាប់ផងដែរនូវឯកសារដែលអាចបញ្ជាក់ពីអត្តសញ្ញាណបុគ្គលរបស់មរណជនជាមួយនឹងពាក្យសុំចុះបញ្ជីមរណភាព។[55]

**គ. ការបញ្ជាក់សំបុត្រមរណភាព**

ពលរដ្ឋខ្មែរដែលស្លាប់មុនពេលអនុក្រឹត្យស្តីពី អត្រានុកូលដ្ឋាន ចូលជាធរមានហើយគ្មានសំបុត្រមរណភាព សាច់ញាតិសន្តានដែលនៅរស់ អាចមកសុំចុះសៀវភៅបញ្ជាក់មរណភាពតាមគំរូណែនាំថ្មីនៅសាលាឃុំ ឬសង្កាត់ដែលញាតិសន្តានរស់នៅជាប់លាប់បច្ចុប្បន្នដោយនាំសាក្សីចំនួន ០២រូបជានីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានដឹងឮផ្ទាល់អំពីការស្លាប់ និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយអ្នកស្លាប់មកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។[56]

## ២.២. សេចក្តីចម្លងអត្រានុកូលដ្ឋាន និងការជូនដំណឹងនៃអត្រានុកូលដ្ឋាន

### ២.២.១. សេចក្តីចម្លងអត្រានុកូលដ្ឋាន

#### ២.២.១.១. សេចក្តីចម្លងអត្រានុកូលដ្ឋានកំណើត និងសម្រង់បញ្ជីកំណើត

ការសុំចម្លង ឬសម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើតក្នុងឆ្នាំមិនទាន់ដាច់ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ ឬសាលាសង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ និងត្រូវបោះត្រាផង។ ការសុំចម្លង ឬសម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើតបញ្ជាក់កំណើតនៅក្នុងឆ្នាំដែលកន្លងផុតទៅត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលាក្រុង ស្រុក ខណ្ឌ។ បើសុំចម្លង ឬសម្រង់នៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអភិបាល ឬអភិបាលរងក្រុង ស្រុក ខណ្ឌ ដែលអភិបាល ក្រុង ស្រុក ខណ្ឌប្រតិភូកម្ម និងបោះត្រាផង។[57]

បុគ្គលដែលអាចស្នើសុំសេចក្តីចម្លងសំបុត្រកំណើតបានរួមមាន សាមីខ្លួននៃសំបុត្រកំណើត ឬញាតិលោហិតផ្ទាល់ និងសហព័ទ្ធរបស់សាមីខ្លួននៃសំបុត្រកំណើត ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិរបស់បុគ្គលខាងលើ បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ស្របច្បាប់ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានយល់ឃើញថាបុគ្គលដែលស្នើសុំសេចក្តីចម្លងសំបុត្រកំណើតមិនមែនជាបុគ្គលខាងលើ ឬការស្នើសុំនោះត្រូវបានធ្វើឡើងក្នុងគោលបំណងមិន

[55] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៥៣

[56] អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា៤៥

[57] កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន, ទំព័រទី៧៤

ត្រឹមត្រូវទេ ដូចជាការមានគោលបំណងធ្វើអោយមានការប៉ះពាល់ភាពឯកជនរបស់សាមីខ្លួននៃសំបុត្រកំណើត មន្ត្រីអត្រានុកូលដ្ឋានត្រូវបដិសេធសំណើនោះ និងត្រូវផ្តល់មូលហេតុសម្រាប់ការបដិសេធនោះ ការបដិសេធនេះ អាចប្តឹងមិនសុខចិត្តបាន។ អាជ្ញាធរមានសមត្ថកិច្ច ឬតុលាការអាចស្នើសុំជាលាយលក្ខណ៍អក្សរនូវសេចក្តីចម្លងសំបុត្រកំណើត ឬសម្រង់បញ្ជីកំណើត នៅក្នុងករណីដែលមានការចាំបាច់ដើម្បីបំពេញនូវកិច្ចការរបស់ខ្លួន ដោយផ្អែកទៅលើច្បាប់ ឬក៏លិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀត។ ក្នុងករណីដែលមានការស្នើសុំបែបនេះមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវផ្តល់ឯកសារដែលបានស្នើរនោះឱ្យបានឆាប់រហ័សដោយឥតគិតថ្លៃ។[58]

## ២.២.១.២. សេចក្តីចម្លងអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងសម្រង់បញ្ជីអាពាហ៍ពិពាហ៍

បុគ្គលដែលអាចស្នើសុំសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍បានរួមមាន៖

- សាមីខ្លួននៃសំបុត្រអាពាហ៍ពិពាហ៍។
- ញាតិលោហិតផ្ទាល់នៃសាមីខ្លួននៃសំបុត្រអាពាហ៍ពិពាហ៍។
- អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិរបស់បុគ្គលខាងលើ។
- បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ស្របច្បាប់ ដែលកំណត់ដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានយល់ឃើញថាបុគ្គលដែលស្នើសុំសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ការស្នើសុំនោះត្រូវបានធ្វើឡើងក្នុងគោលបំណងមិនត្រឹមត្រូវដូចជាគោលបំណងធ្វើឱ្យមានការប៉ះពាល់ភាពឯកជនរបស់សាមីខ្លួននៃសំបុត្រអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវបដិសេធសំណើនោះ និងត្រូវផ្តល់មូលហេតុសម្រាប់ការបដិសេធនោះ ការបដិសេធនេះអាចប្តឹងមិនសុខចិត្តបាន (បណ្តឹងមិនសុខចិត្ត)។ អាជ្ញាធរមានសមត្ថកិច្ច ឬតុលាការអាចធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរនូវសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសម្រង់បញ្ជីអាពាហ៍ពិពាហ៍ នៅក្នុងករណីដែលមានការចាំបាច់ដើម្បីបំពេញកិច្ចការរបស់ខ្លួនដោយផ្អែកលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។ ក្នុងករណីដែលមានការស្នើសុំបែបនេះមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវផ្តល់ឯកសារដែលបានស្នើសុំឱ្យបានឆាប់រហ័សដោយឥតគិតថ្លៃ។ សំបុត្រអាពាហ៍ពិពាហ៍ និងសេចក្តីចម្លង

[58] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា២៨

សំបុត្រអាពាហ៍ពិពាហ៍ត្រូវមានលក្ខណៈសម្គាល់ជានាសុវត្ថិភាពដើម្បីការពារការក្លែងបន្លំនានា។ ទម្រង់សំបុត្រអាពាហ៍ពិពាហ៍ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[59]

ការសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ក្នុងឆ្នាំមិនទាន់ដាច់ឆ្នាំ ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ សង្កាត់ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ហើយត្រូវបោះត្រាផង។ ការសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ នៅក្នុងឆ្នាំដែលកន្លងផុតទៅត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលាក្រុង ស្រុក ខណ្ឌសាមី និងនៅក្រសួងមហាផ្ទៃ។ នៅពេលពិនិត្យសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឃើញថាជាសំបុត្រច្បាប់ដើមពិតប្រាកដហើយ ទើបមន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីសៀវភៅអត្រានុកូលដ្ឋាន អាចចាប់ផ្តើមសរសេរចូលសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍។ ការសរសេរចូលក្នុងសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ដោយត្រូវចម្លងចេញពីសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ បើសិនសុំសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ចម្លងចេញពីសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍បើសុំសេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍។[60]

### ២.២.១.៣. សេចក្តីចម្លងអត្រានុកូលដ្ឋានមរណភាព និងសម្រង់បញ្ជីមរណភាព

សម្រង់សំបុត្រមរណភាព សម្រង់សំបុត្របញ្ជាក់មរណភាពត្រូវស្រង់ចេញពីសៀវភៅអត្រានុកូលដ្ឋានមរណភាព និងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ដែលតម្កល់ទុកដោយស្រង់យកតែខ្លឹមសារតាមសំណើរបស់អ្នកមកសុំស្រង់តែប៉ុណ្ណោះ។[61]

ចំពោះការសុំចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព ឬអ្នកស្នើសុំត្រូវយកសំបុត្រមរណភាពច្បាប់ដើមមកជាមួយ។ ក្នុងករណីបាត់បង់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម អ្នកមកសុំអាចសុំចម្លងបានត្រូវមានលក្ខខណ្ឌដូចជា រាយការណ៍ជាលាយលក្ខណ៍អក្សរឱ្យបានច្បាស់លាស់ អំពីមូលហេតុនៃការបាត់បង់ និងត្រូវបញ្ជាក់ពីឃុំ សង្កាត់លេខសៀវភៅ ឬលេខបញ្ជី និងឆ្នាំដែលបានចុះសៀវភៅអត្រានុកូលដ្ឋាន។[62]

[59] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៧២-៧៣

[60] កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន, ទំព័រទី១១៥-១១៦

[61] កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន, ទំព័រទី១៧៣

[62] កម្រងឯកសារ ស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន, ទំព័រទី១៦៣

**បុគ្គលដែលអាចស្នើសុំសេចក្តីចម្លងសំបុត្រមរណភាព និងសម្រង់បញ្ជីមរណភាពបានមាន៖**

- ញាតិនៃមរណជន។
- អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិរបស់ញាតិនៃមរណជន។
- បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ស្របច្បាប់ ដែលកំណត់ដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានយល់ឃើញថាបុគ្គលស្នើសុំសេចក្តីចម្លងសំបុត្រមរណភាព និងសម្រង់បញ្ជីមរណភាព ស្នើសុំនោះត្រូវបានធ្វើឡើងក្នុងគោលបំណងមិនត្រឹមត្រូវ ដូចជាគោលបំណងធ្វើឱ្យមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ញាតិនៃមរណជន មន្ត្រីអត្រានុកូលដ្ឋានត្រូវបដិសេធសំណើនោះ និងត្រូវផ្តល់មូលហេតុសម្រាប់ការបដិសេធនោះ។

អាជ្ញាធរមានសមត្ថកិច្ច ឬតុលាការអាចស្នើសុំជាលាយលក្ខណ៍អក្សរនូវសេចក្តីចម្លងសំបុត្រមរណភាព ឬសម្រង់បញ្ជីមរណភាព ក្នុងករណីដែលមានការចាំបាច់ដើម្បីបំពេញកិច្ចការរបស់ខ្លួន ដោយផ្អែកលើច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ នៅក្នុងករណីមានការស្នើសុំបែបនេះ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវផ្តល់ឯកសារដែលបានស្នើសុំឱ្យបានឆាប់រហ័សដោយឥតគិតថ្លៃ។[63]

### ២.២.២. ការជូនដំណឹងនៃអត្រានុកូលដ្ឋាន

#### ២.២.២.១. ការជូនដំណឹងអំពីកំណើត

**ក. អ្នករាយការណ៍**

បុគ្គលទទួលខុសត្រូវជាអ្នករាយការណ៍អំពីកំណើតរស់ ត្រូវបានកំណត់តាមអាទិភាពដូចខាងក្រោម៖

- ម្តាយរបស់ទារក។
- ឪពុករបស់ទារក។
- អ្នកអាណាព្យាបាលទូទៅរបស់ឪពុកម្តាយទារក។
- ញាតិជានីតិជនដែលមើលថែទារក។
- រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអ្នកតំណាង ឬបុគ្គលផ្សេងទៀតដែលកំណត់ដោយច្បាប់។

[63] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៥៦

- ក្នុងករណីដែលមានការចាំបាច់អ្នកដែលរាយការណ៍ក្រៅពីបុគ្គលដែលបានកំណត់ខាងលើត្រូវកំណត់ដោយអនុក្រឹត្យ។[64]

**ខ. ការជូនដំណឹងកំណើតនៅក្នុងមូលដ្ឋានសុខាភិបាល**

ប្រធាន ឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាលដែលកំណើតរស់បានកើតឡើង ត្រូវផ្តល់ឯកសារដែលបញ្ជាក់អំពីកំណើតរស់ទៅឱ្យអ្នកដែលរាយការណ៍ទៅតាមអាទិភាព (អ្នករាយការណ៍អំពីកំណើតរស់)។ ប្រសិនបើទារកកើតនៅក្រៅមូលដ្ឋានសុខាភិបាល ហើយម្តាយ និងទារកធ្វើដំណើរទៅមូលដ្ឋានសុខាភិបាលក្នុងរយៈពេល៤៨ (សែសិបប្រាំបី)ម៉ោង ប្រធាន ឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាល ត្រូវផ្តល់ឯកសារបញ្ជាក់អំពីកំណើតរស់ឱ្យទៅអ្នករាយការណ៍ទៅតាមអាទិភាព។

ប្រធាន ឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាល ត្រូវផ្ញើច្បាប់ចម្លងនៃឯកសារបញ្ជាក់ អំពីកំណើតរស់នោះមួយច្បាប់ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច។ ទម្រង់ បែបបទ និងនីតិវិធីសម្រាប់ការផ្តល់ឯកសារបញ្ជាក់អំពីកំណើតរស់ដល់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច។[65]

**គ. ការជូនដំណឹងកំណើតនៅក្រៅមូលដ្ឋាន**

ការជូនដំណឹងអំពីកំណើតរស់ដែលកើតនៅក្រៅមូលដ្ឋានសុខាភិបាល ប្រសិនបើកំណើតរស់កើតនៅក្រៅមូលដ្ឋានសុខាភិបាល ហើយម្តាយ និងទារកមិនបានធ្វើដំណើរទៅកាន់មូលដ្ឋានសុខាភិបាលក្នុងរយៈពេល៤៨ (សែសិបប្រាំបី)ម៉ោង បុគ្គល ឬស្ថាប័នដែលបានដឹងពីព្រឹត្តិការណ៍កំណើតរស់នេះអាចតម្រូវឱ្យផ្តល់ព័ត៌មាន ឬឯកសារដូចដែលកំណត់នៅក្នុងប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។[66]

**២.២.២.២. ការជូនដំណឹងនៃអាពាហ៍ពិពាហ៍**

ការជូនដំណឹងជាសាធារណៈអំពីការរៀបអាពាហ៍ពិពាហ៍មានដូចជា៖

- មន្ត្រីអត្រានុកូលដ្ឋានត្រូវផ្សព្វផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍ តាមរយៈការបិទប័ណ្ណប្រកាសមួយច្បាប់នៅលំនៅឋានរបស់នារី និងមួយច្បាប់ទៀតនៅសាលាឃុំ សង្កាត់ នៃលំនៅឋានរបស់នារី និងត្រូវបញ្ជូនប័ណ្ណប្រកាសចំនួនពីរច្បាប់ទៀតទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលបុរសរស់នៅ

[64] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា២០

[65] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា២១

[66] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា២២

ដើម្បីបិទប័ណ្ណប្រកាសនោះមួយច្បាប់នៅលំនៅឋានរបស់បុរស និងមួយច្បាប់ទៀតបិទនៅសាលាឃុំ សង្កាត់នៃលំនៅឋានរបស់បុរសនោះ។

- ទម្រង់ និងព័ត៌មាននៃប័ណ្ណប្រកាសនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- ការប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍ត្រូវធ្វើឡើងជាប់គ្នាជាបន្តបន្ទាប់នៅក្នុងរយៈពេលដប់ថ្ងៃ ក្នុងគោលបំណងបង្កលក្ខណៈឱ្យជនដែលមានផលប្រយោជន៍នៅក្នុងរឿងនេះអាចប្ដឹងជំទាស់អាពាហ៍ពិពាហ៍នេះបាននៅក្នុងរយៈពេលដប់ថ្ងៃនោះ។ ប្រសិនបើគ្មានការជំទាស់នៅក្នុងរយៈពេលដប់ថ្ងៃនោះទេ អាពាហ៍ពិពាហ៍អាចធ្វើឡើងគ្រប់ពេលវេលានៅក្នុងរយៈពេលប្រាំមួយខែគិតចាប់ពីថ្ងៃដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍។
- ប្រសិនបើបុរស និងនារីដែលបានដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍នោះ ប៉ុន្តែមិនបានមកចុះបញ្ជីអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចទេនោះ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចអាចរំលឹកដោយការជូនដំណឹងទៅបុរស និងនារីនោះបាន។[67]

មន្ត្រីអត្រានុកូលដ្ឋានត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ដែលគ្រោងនឹងធ្វើនោះផ្សាយជាសាធារណៈនៅលំនៅដ្ឋាន និងនៅសាលាឃុំ ឬសាលាសង្កាត់នៃសាមីខ្លួននារី ០១ច្បាប់។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ពីរច្បាប់ទៀតត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ខាងបុរសដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និងបិទនៅសាលាឃុំ ឬសង្កាត់នៃសាមីខ្លួនបុរស មួយច្បាប់។

**ចំពោះប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវចុះព័ត៌មានដូចជា៖**

- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅឋាននៃអនាគតប្តីប្រពន្ធ។
- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅរបស់ឪពុកម្ដាយ នៃអនាគតប្តីប្រពន្ធ បើឪពុក ឬម្ដាយស្លាប់ ត្រូវដាក់ថាស្លាប់។
- រយៈពេលប្ដឹងជំទាស់។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ត្រូវបិទផ្សាយនៅក្នុងរយៈពេលដប់ថ្ងៃមុនថ្ងៃរៀបអាពាហ៍ពិពាហ៍ដើម្បីឱ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនេះអាចប្ដឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្រប

[67] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៦៩

នឹងអាពាហ៍ពិពាហ៍នោះ។ ផុតរយៈពេលដប់ថ្ងៃ អាពាហ៍ពិពាហ៍អាចធ្វើទៅបានបើគ្មានការប្តឹងជំទាស់។ បើមានបណ្តឹងជំទាស់នឹងអាចរៀបអាពាហ៍ពិពាហ៍បានលុះត្រាតែបណ្តឹងជំទាស់ត្រូវបានសមត្ថកិច្ចដោះស្រាយចប់។[68]

### ២.២.២.៣. ការជូនដំណឹងនៃមរណភាព

មរណភាព គឺជាព្រឹត្តិការណ៍គតិយុត្តដែលនាំឱ្យបុគ្គលិកលក្ខណៈរបស់រូបវន្តបុគ្គលម្នាក់ត្រូវបានបញ្ចប់ ប៉ុន្តែច្បាប់បានកំណត់ទទួលស្គាល់ និងបានផ្តល់អនុភាពខាងផ្លូវច្បាប់មួយចំនួនដូចជាមរតកសាសន៍ជាដើម។ ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ចនៅក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ត្រូវតែរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬសង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់។ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសព បើស្លាប់ដោយជម្ងឺធម្មតា ដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬដោយគ្រោះថ្នាក់ផ្សេងៗទៀតដែលមិនមានមន្ទិលសង្ស័យទាក់ទងដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋណាមួយ។

ការចុះសៀវភៅមរណភាព និងចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព។ បើអ្នកស្លាប់ដោយជម្ងឺឆ្លងរាតត្បាត អាចបណ្តាលឱ្យគ្រោះថ្នាក់ដល់សង្គមត្រូវរាយការណ៍ទៅមន្ទីរពេទ្យ ឬផ្នែកអនាម័យភ្លាម។ បើពេទ្យ ឬផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពតាមការសម្រេចនោះ។[69]

#### ក. អ្នករាយការណ៍អំពីមរណភាព

បុគ្គលដែលទទួលខុសត្រូវជាអ្នករាយការណ៍អំពីមរណភាពត្រូវបានកំណត់ដូចខាងក្រោម៖

- សម្រាប់មរណភាពរបស់អនីតិជន ម្តាយឪពុក ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន សាច់ញាតិជានីតិជនរបស់មរណជន រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ឬអ្នកតំណាង ឬបុគ្គលផ្សេងទៀតដែលកំណត់ដោយច្បាប់នេះ ឬច្បាប់ផ្សេងទៀត។
- សម្រាប់មរណភាពរបស់នីតិជន សហព័ទ្ធរបស់មរណជន ញាតិជានីតិជនរបស់មរណជន រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអ្នកតំណាង ឬបុគ្គលផ្សេងទៀតដែលកំណត់ដោយច្បាប់នេះ ឬច្បាប់ផ្សេងទៀត។

---

[68] អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា២៩

[69] អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា៣៥

- សម្រាប់មរណភាពដោយសារមូលហេតុខុសប្រក្រតី ឬគួរឱ្យសង្ស័យ ឬបណ្ដាលពី គ្រោះមហន្តរាយធម្មជាតិ ឬគ្រោះអាសន្នទ្រង់ទ្រាយធំ ត្រូវរាយការណ៍ដោយបុគ្គល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធតាមការកំណត់ដោយបទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។
- ប្រសិនបើអ្នករាយការណ៍ជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ ទម្រង់ បែបបទ និងនីតិវិធីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[70]

### ខ. ការជូនដំណឹងអំពីមរណភាពដែលកើតឡើងក្នុងមូលដ្ឋានសុខាភិបាល

ប្រធាន ឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាលដែលមរណភាពបានកើតឡើងត្រូវផ្ដល់ឯកសារបញ្ជាក់អំពីមរណភាពមួយច្បាប់ ទៅឱ្យអ្នករាយការណ៍ទៅតាមអាទិភាព។ ប្រធាន ឬក៏បុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាល ត្រូវផ្ដល់ឯកសារបញ្ជាក់អំពីមរណភាពឱ្យអ្នករាយការណ៍ប្រសិនបើមរណភាពរបស់ជននោះ កើតឡើងមុនពេលទៅដល់មូលដ្ឋានសុខាភិបាល ហើយបានធ្វើដំណើរទៅដល់មូលដ្ឋានសុខាភិបាល។

ក្នុងករណីដែលបានកំណត់នៅខាងលើនេះប្រធាន ឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាលត្រូវបញ្ជូនច្បាប់ចម្លងនៃឯកសារដែលបានធ្វើការបញ្ជាក់អំពីមរណភាពនោះមួយច្បាប់ទៅដល់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច។ ទម្រង់ បែបបទ និងនីតិវិធីសម្រាប់ការផ្ដល់ឯកសារបញ្ជាក់អំពីមរណភាពដល់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។[71]

### គ. ការជូនដំណឹងអំពីមរណភាពនៅក្រៅមូលដ្ឋាន

ប្រសិនបើមរណភាពដែលកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល អ្នករាយការណ៍ត្រូវរាយការណ៍អំពីមរណភាពទៅអាជ្ញាធរមានសមត្ថកិច្ច។ អាជ្ញាធរមានសមត្ថកិច្ច ត្រូវសហការជាមួយមូលដ្ឋានសុខាភិបាលធ្វើការត្រួតពិនិត្យដើម្បីឱ្យមូលដ្ឋានសុខាភិបាលបញ្ជាក់អំពីមរណភាព និងផ្ដល់ឯកសារបញ្ជាក់អំពីមរណភាពទៅឱ្យអ្នករាយការណ៍។ មូលដ្ឋានសុខាភិបាលត្រូវបញ្ជូនច្បាប់ចម្លងនៃឯកសារបញ្ជាក់អំពីមរណភាពមួយច្បាប់ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច។ ទម្រង់ បែបបទ និងនីតិវិធីសម្រាប់ការផ្ដល់ឯកសារបញ្ជាក់អំពីមរណភាព

[70] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៤៤

[71] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៤៥

ដល់មន្ត្រី អត្រានុកូលដ្ឋានមានសមត្ថកិច្ច ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល។[72]

## ២.៣. បញ្ហាប្រឈម និងដំណោះស្រាយ

សំបុត្រអត្រានុកូលដ្ឋានពិតជាមានសារៈសំខាន់ណាស់ ប្រសិនបើគ្មានការចុះសំបុត្រអត្រានុកូលដ្ឋាន ត្រឹមត្រូវទេនោះវានឹងនាំឱ្យមានបញ្ហាដល់ខ្លួនឯង និងសង្គមដូចជាមិនអាចធ្វើការងារ បើកអាជីវកម្ម និងតវ៉ា ចំពោះមុខច្បាប់អំពីបញ្ហានានាបាននោះទេ។ ប្រជាពលរដ្ឋអាចទៅសុំធ្វើសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាពនៅសាលាឃុំ ឬសង្កាត់ និងការិយាល័យច្រកចេញចូលតែមួយ។

### ២.៣.១. បញ្ហាប្រឈមនៃការចុះបញ្ជីអត្រានុកូលដ្ឋាន

ការចុះបញ្ជីអត្រានុកូលដ្ឋាននៅកម្ពុជានៅមិនទាន់មានលក្ខណៈបច្ចេកទេសទំនើបដែលអាចចុះបញ្ជី និងអាចរក្សាទិន្នន័យតាមប្រព័ន្ធឌីជីថលនៅឡើយនោះទេ។ ការចុះបញ្ជីអត្រានុកូលដ្ឋាន គឺធ្វើឡើងតែនៅក្នុង សៀវភៅ និងសំបុត្រអត្រានុកូលដ្ឋានតែប៉ុណ្ណោះ ដែលអាចប្រឈម និងហានិភ័យដូចជា កើតមានគ្រោះទឹក ជំនន់ អគ្គីភ័យ ការធ្វេសប្រហែសក្នុងការទុកដាក់សៀវភៅរបស់មន្ត្រីអត្រានុកូលដ្ឋាន ការសឹករិចរិលនៃក្រដាស និងករណីប្រធានសក្តិផ្សេងៗទៀត ដែលធ្វើឱ្យបាត់បង់នូវទិន្នន័យដើមដែលបង្ករជាផលវិបាកជាច្រើនដល់ទៅ អាជ្ញាធរមានសមត្ថកិច្ច និងប្រជាពលរដ្ឋ។

ចំពោះបញ្ហាប្រឈមអំពីការចុះបញ្ជីអត្រានុកូលដ្ឋាននៅកម្ពុជា តាមរយៈការសិក្សាផ្ទៀងផ្ទាត់ទិន្នន័យ ប្រជាពលរដ្ឋនាពេលកន្លងមក ក្រសួងមហាផ្ទៃបានកត់សម្គាល់ ឃើញថាប្រជាពលរដ្ឋប្រមាណជិត៣៥ភាគរយ កំពុងជួបប្រទះបញ្ហាខុសទិន្នន័យអត្តសញ្ញាណរបស់ខ្លួននៅក្នុងបញ្ជី និងសំបុត្រអត្រានុកូលដ្ឋានជាមួយនឹង ឯកសារអត្តសញ្ញាណដទៃទៀត ហើយប្រជាពលរដ្ឋខ្លះបានចុះបញ្ជីអត្រានុកូលដ្ឋានប្រភេទតែមួយលើសពីមួយ ដង ជាពិសេសការចុះបញ្ជីក្នុងអំឡុងពេលយុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័ត ដែលបានធ្វើឱ្យសាមីខ្លួន ជួបការលំបាកយ៉ាងខ្លាំងក្នុងការស្នើសុំសេវារដ្ឋបាលផ្សេងៗ។ រីឯនីតិវិធីក្នុងការកែតម្រូវ និងការមោឃភាពបញ្ជី អត្រានុកូលដ្ឋានបច្ចុប្បន្នមានភាពលំបាកស្មុគស្មាញដែលមិន អាចឆ្លើយតបបានទៅនឹងសំណូមពររបស់ប្រជា ពលរដ្ឋ។ ដោយយោងតាមអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ដែលស្តីពីមន្ត្រី អត្រានុកូលដ្ឋានថ្នាក់ជាតិក៏បានផ្តល់សមត្ថកិច្ចមួយចំនួនដល់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិក្នុងការត្រួតពិនិត្យ សម្រេច និងអនុញ្ញាតឱ្យកែតម្រូវទិន្នន័យអត្រានុកូលដ្ឋាន ឬអនុញ្ញាតឱ្យចុះបញ្ជីអត្រានុកូលដ្ឋានឡើងវិញស្រប

[72] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៤៦

តាមបទប្បញ្ញត្តិច្បាប់។ អនុវត្តតាមស្មារតីនៃអនុក្រឹត្យនេះក្រសួងមហាផ្ទៃធ្វើការណែនាំអំពីការកែតម្រូវ និងការធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ដើម្បីដោះស្រាយការលំបាកចំពោះមុខរបស់ប្រជាពលរដ្ឋ។[73]

### ២.៣.២. ដំណោះស្រាយចំពោះបញ្ហាប្រឈមនៃការចុះបញ្ជីអត្រានុកូលដ្ឋាន

អនុលោមតាមអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន ការចុះបញ្ជីអត្រានុកូលដ្ឋានតាមគំរូថ្មីឯកភាពត្រូវបានដាក់ឱ្យដំណើរការក្នុងក្របខ័ណ្ឌជាតិទាំងមូលចាប់តាំងពីថ្ងៃទី១ ខែសីហា ឆ្នាំ២០០២ មក។ ក្នុងរយៈពេលនេះដើម្បីលើកកម្ពស់ការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋ រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឱ្យបង្កើតនូវយុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័តចំនួនបីលើកជាប់ៗគ្នាចាប់តាំងពីថ្ងៃទី១ ខែតុលា ឆ្នាំ២០០៤ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៦។ ផ្អែកតាមគោលនយោបាយ និងវិធានការទាំងនេះរួមនឹងការខិតខំប្រឹងប្រែងដោយផ្ទាល់របស់អាជ្ញាធរឃុំ សង្កាត់ទូទាំងប្រទេសដោយមានការគាំទ្រពីក្រសួង ស្ថាប័ននានានៅថ្នាក់ជាតិ អាជ្ញាធរខេត្ត ក្រុង ស្រុក ខណ្ឌ ព្រមទាំងអង្គការជាតិ និងអន្តរជាតិនានា បានធ្វើឱ្យការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋ សម្រេចបានលទ្ធផលគួរជាទីមោទនៈ។ ប៉ុន្តែប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានតាមគំរូថ្មីឯកភាពជាកិច្ចការថ្មីថ្មោង ការបណ្តុះបណ្តាល និងកសាងសមត្ថភាព ធ្វើឡើងក្នុងរយៈពេលខ្លីចំពោះមន្ត្រីរាជការទទួលកិច្ចការនេះក៏មានចំនួនតិចតួចនៅឡើយ រីឯការអប់រំសាធារណជន ក៏ធ្វើឡើងមិនទាន់បានទូលំទូលាយ ហើយការចុះបញ្ជីអត្រានុកូលដ្ឋានបានធ្វើឡើងក្នុងលក្ខណៈប្រញាប់ប្រញាល់នៅក្នុងដំណាក់កាលនៃការចុះបញ្ជីអត្រានុកូលដ្ឋានចល័តជាហេតុធ្វើឱ្យមានការខុសឆ្គង និងការភ័ន្តច្រឡំមួយចំនួនក្នុងការស្រង់ព័ត៌មានរបស់ប្រជាពលរដ្ឋបញ្ចូលទៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ដូចជានាមត្រកូល នាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើត សាក្សី ឈ្មោះខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ ជាដើម។

ការខុសឆ្គង និងការភ័ន្តច្រឡំទាំងនេះចាំបាច់ត្រូវធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាដើម្បីកត់ត្រាអោយបានច្បាស់លាស់ពិតប្រាកដនូវស្ថានភាពជាក់ស្តែង និងស្របច្បាប់របស់បុគ្គលម្នាក់ៗដែលចុះនៅក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ។ ទន្ទឹមនេះការផ្លាស់ប្តូរណាមួយមកលើឋានៈ និងស្ថានភាពរបស់បុគ្គលម្នាក់ៗតាមការសម្រេចរបស់តុលាការក៏ចាំបាច់ត្រូវធ្វើការកត់ត្រាចូលទៅក្នុងបញ្ជីអត្រានុកូលដ្ឋានឱ្យបានត្រឹមត្រូវផងដែរ។ អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន មាត្រា១៣ បានចែងអំពីនីតិវិធីកែតម្រូវសៀវភៅអត្រានុកូលដ្ឋាន។ ទន្ទឹមនេះមាត្រា៩ នៃអនុក្រឹត្យខាងលើនេះក៏បានកំណត់អំពីភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានដែលក្នុងនោះមានទាំងការកែតម្រូវអក្ខរាវិរុទ្ធ ការកែតម្រូវ ឬការបដិសេធ

[73] សេចក្តីណែនាំ ស្តីពីការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន, លេខ០៣៥ សណន, ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ ២០១៧

អត្រានុកូលដ្ឋាន តាមអំណាចសាលក្រមស្ថាពរ របស់តុលាការ។ អនុក្រឹត្យនេះក៏បានកំណត់ អំពីភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានក្នុងការចុះកិច្ចសន្យាសុំកូននៅក្នុងសៀវភៅអត្រានុកូលដ្ឋានផងដែរ។ ដើម្បីកែតម្រូវនូវការខុសឆ្គង ការភ័ន្តច្រឡំនានានៅក្នុងសៀវភៅអត្រានុកូលដ្ឋានដែលបានប្រើប្រាស់កន្លងមក និងការកែតម្រូវ និងបដិសេធអត្រានុកូលដ្ឋាន តាមអំណាចសាលក្រមស្ថាពររបស់តុលាការ និងការចុះកិច្ចសន្យាសុំកូនយកទៅចិញ្ចឹមនៅក្នុងសៀវភៅអត្រានុកូលដ្ឋាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[74]

**ទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានអាចកែតម្រូវបាន គឺជាទិន្នន័យដែលសរសេរខុស ឬភាន់ច្រឡំព័ត៌មានដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់មានដូចខាងក្រោម៖**

- ការខុសឆ្គងអក្ខរាវិរុទ្ធ នាមត្រកូល ឬនាមខ្លួន ជាអក្សរខ្មែរ និងអក្សរឡាតាំង របស់សាមីខ្លួន ឬរបស់ឪពុក ឬរបស់ម្តាយមានន័យថាសូរសំឡេងដូចគ្នា ឬក៏ប្រហាក់ប្រហែលគ្នា ក៏ប៉ុន្តែការសរសេរខុសគ្នា។
- ការសរសេរខុសភេទ នៅពេលចុះបញ្ជីដូចជា ភេទប្រុសតែសរសេរដាក់ថាភេទស្រី ឬភេទស្រីតែសរសេរដាក់ថាភេទប្រុស។
- ការចុះបញ្ជីដោយភ័ន្តច្រឡំលើថ្ងៃ ខែ ឆ្នាំកំណើតរបស់សាមីខ្លួន ឬរបស់ឪពុក ឬរបស់ម្តាយ។
- ខុសថ្ងៃកំណើតចន្ទសុរិយគតិ ដូចជាសរសេរដាក់ថ្ងៃច័ន្ទ ទី១៣ ខែមេសា ឆ្នាំ១៩៧២ ប៉ុន្តែជាក់ស្តែងថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧២ ជាថ្ងៃព្រហស្បតិ៍។
- ការភាន់ច្រឡំទីតាំងភូមិសាស្ត្ររដ្ឋបាល ដូចជាសរសេរដាក់ថា ស្រុកកំពង់សៀម ខេត្តកំពង់ស្ពឺ ប៉ុន្តែជាក់ស្តែងស្រុកកំពង់សៀម ស្ថិតក្នុងខេត្តកំពង់ចាម។
- ខ្វង់ទីកន្លែងកំណើត បានសរសេរខុសពីទីកន្លែងកំណើតដែលសាមីខ្លួនបានកើតជាក់ស្តែង ឬសរសេរខុសទីតាំងភូមិសាស្ត្ររដ្ឋបាលនាសម័យដែលបុគ្គលនោះកើត ឧទាហរណ៍ថាបញ្ជីកំណើតរបស់បុគ្គលម្នាក់បានចុះថា កើតឆ្នាំ១៩៨៥ នៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ប៉ុន្តែក្នុងអំឡុងឆ្នាំ១៩៨៥ ស្រុកមង្គលបុរីស្ថិតនៅក្នុងខេត្តបាត់ដំបងពីព្រោះនៅមិនទាន់បង្កើតខេត្តបន្ទាយមានជ័យនៅឡើយទេ។
- ការខកខានមិនបានចុះព័ត៌មាននៅក្នុងបញ្ជីអត្រានុកូលដ្ឋាន លើកលែងតែការបន្ថែមទិន្នន័យព័ត៌មានណាដែលធ្វើឱ្យសាមីខ្លួនរួចផុតពីការទទួលខុសត្រូវខាងផ្លូវច្បាប់។
- សម្រេចមោឃភាពលើបញ្ជីអត្រានុកូលដ្ឋាន និងដកហូតសំបុត្រអត្រានុកូលដ្ឋានទាំងឡាយណាដែលបានចុះជាន់គ្នា ឬចុះខុសពីបែបបទនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។

[74] សេចក្តីណែនាំអន្តរក្រសួង ស្តីពីការកែតម្រូវនិងបំពេញចំណុចខ្វះខាតនៅក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ

- កែតម្រូវទិន្នន័យអត្រានុកូលដ្ឋានតាមសេចក្ដីសម្រេចរបស់តុលាការ។[75]

**នៅពេលមានការខុសអត្រានុកូលដ្ឋានបុគ្គលដែលអាចស្នើសុំកែតម្រូវបញ្ជីអត្រានុកូលដ្ឋានរួមមាន៖**

- សាមីខ្លួននៃបញ្ជីអត្រានុកូលដ្ឋាន។
- ឪពុក ម្ដាយ ឬអាណាព្យាបាលរបស់អនីតិជនក្នុងករណីសុំកែតម្រូវបញ្ជីកំណើតរស់របស់អនីតិជន។
- ញាតិលោហិតផ្ទាល់ និងសហព័ទ្ធនៃមរណជន ក្នុងករណីសុំកែតម្រូវបញ្ជីមរណភាព។
- បុគ្គលទាំងឡាយណាដែលមានផលប្រយោជន៍ស្របច្បាប់ក្នុងការកែតម្រូវបញ្ជីអត្រានុកូលដ្ឋានតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[76]

**ក្រៅពីកំហុសបច្ចេកទេសរបស់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច (ការកែតម្រូវកំហុសបច្ចេកទេសដោយមន្ត្រីអត្រានុកូលដ្ឋាន) ការកែតម្រូវបញ្ជីអត្រានុកូលដ្ឋានត្រូវធ្វើឡើងតាមរយៈការដាក់ពាក្យសុំទៅតុលាការ៖**

- ក្នុងករណីដែលសេចក្ដីសម្រេចកែតម្រូវរបស់តុលាការបានចូលជាស្ថាពរ អ្នកដាក់ពាក្យសុំទៅតុលាការត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលបានចុះបញ្ជីអត្រានុកូលដ្ឋាន ដែលត្រូវកែតម្រូវ ឬឃុំ សង្កាត់នៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំ ឬឃុំ សង្កាត់ដែលបានកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយភ្ជាប់នឹងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ នៃសេចក្ដីសម្រេចរបស់តុលាការនោះ និងសេចក្ដីបញ្ជាក់អំពីថ្ងៃដែលសេចក្ដីសម្រេចរបស់តុលាការនោះ បានចូលជាស្ថាពរ ក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ ដោយគិតពីថ្ងៃដែលសេចក្ដីសម្រេចរបស់តុលាការ នោះបានចូលជាស្ថាពរ។
- ក្នុងករណីដែលសេចក្ដីសម្រេចកែតម្រូវបានចូលជាស្ថាពរនៅសាលាដំបូងរាជធានី ខេត្ត លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី ខេត្តដែលចេញសេចក្ដីសម្រេចនោះ ត្រូវជូនដំណឹង អំពីសេចក្ដីសម្រេចនោះទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ដែលសាលាដំបូងនោះស្ថិតនៅ។
- ក្នុងករណីដែលសេចក្ដីសម្រេចខាងលើនេះ បានចូលជាស្ថាពរនៅសាលាឧទ្ធរណ៍ អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ដែលចេញសេចក្ដីសម្រេចនោះ ត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនោះទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

[75] សេចក្ដីណែនាំ ស្ដីពីការបន្តដំណើរការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន, លេខ០៤៥ សណន, ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១៩

[76] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៨៥

- ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានបានទទួលការជូនដំណឹង ទោះបីជាគ្មានការរាយការណ៍ពីអ្នកដែលដាក់ពាក្យសុំទៅតុលាការក៏ដោយក៏មន្ត្រីអត្រានុកូលដ្ឋាននោះអាចកែតម្រូវបានដែរ។ នៅក្នុងករណីនេះមន្ត្រីអត្រានុកូលដ្ឋានត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំទៅតុលាការនោះ។[77]

[77] ច្បាប់លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣, មាត្រា៨៧

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវអំពីប្រធានបទស្តីពី នីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាននៅកម្ពុជា រួចមកបានបង្ហាញឱ្យឃើញថាអត្រានុកូលដ្ឋាន គឺជាឯកសារគតិយុត្តដ៏សំខាន់បំផុតសម្រាប់ប្រជាពលរដ្ឋ និងជាភស្តុតាងដ៏មានតម្លៃបំផុតក្នុងជីវិតរបស់មនុស្សម្នាក់ៗសម្រាប់បញ្ជាក់អំពីអត្តសញ្ញាណ និងស្ថានភាពស៊ីវិលរបស់ខ្លួនដើម្បីទទួលបានសិទ្ធ ករណីកិច្ច របស់ប្រជាពលរដ្ឋម្នាក់ៗនៅក្នុងត្រកូលគ្រួសារ និងសង្គមជាតិផងដែរ។

ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបមានកាតព្វកិច្ចក្នុងការស្នើសុំចុះបញ្ជីអត្រានុកូលដ្ឋាន ព្រោះអត្រានុកូលដ្ឋានគឺជាចំណងភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែងដែលបុគ្គលមាននៅក្នុងត្រកូលគ្រួសារ និងនៅក្នុងសង្គមជាតិ។ បញ្ជីអត្រានុកូលដ្ឋានមាន បញ្ជីកំណើតរស់ បញ្ជីអាពាហ៍ពិពាហ៍ និងបញ្ជីមរណភាព រាល់ការសុំចុះបញ្ជីអត្រានុកូលដ្ឋាន គឺត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ការចុះបញ្ជីអត្រានុកូលដ្ឋានមានសារៈសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋទាំងអស់គ្នា និងប្រទេសជាតិទាំងមូល។ ប្រជាពលរដ្ឋទាំងអស់ត្រូវសុំចុះបញ្ជីអត្រានុកូលដ្ឋានដើម្បីទទួលបានសិទ្ធិពេញលេញជាពលរដ្ឋស្របច្បាប់ និងដើម្បីទទួលបានសិទ្ធិជាច្រើនដូចជា សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គមកិច្ច សិទ្ធិនយោបាយ សិទ្ធិទទួលបានការអប់រំ និងការងារ សិទ្ធិកាន់កាប់កម្មសិទ្ធិ សិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត សិទ្ធិទទួលបានយុត្តិធម៌ និងការជំនុះជម្រះក្តីដោយយុត្តិធម៌ផងដែរ។ ចំពោះការស្នើសុំចុះបញ្ជីអត្រានុកូលដ្ឋានកំណើត គឺឪពុកម្តាយ ឬអាណាព្យាបាលរបស់ទារកត្រូវទៅរាយការណ៍ដើម្បីស្នើសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតឱ្យទារកដែលទើបនឹងកើតនៅក្នុងរយៈពេលកំណត់ ៣០ថ្ងៃនៅសាលាឃុំ សង្កាត់ដែលខ្លួនរស់នៅ។ ចំណែកឯ ការស្នើសុំចុះបញ្ជីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍វិញ គឺសាមីខ្លួនត្រូវទៅសុំចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅឃុំ ឬសង្កាត់ដែលបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍របស់ខ្លួននោះ។ ចំពោះការស្នើសុំចុះបញ្ជីអត្រានុកូលដ្ឋានមរណភាព គឺក្រុមគ្រួសារ ឬសាច់ញាតិបងប្អូន ឬអ្នកមានភារកិច្ចនៅក្នុងក្រសួងស្ថាប័នរបស់មរណជនត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃទីកន្លែងរស់នៅរបស់មរណជនដើម្បីស្នើសុំចុះបញ្ជីមរណភាពឱ្យអ្នកដែលទទួលមរណភាពនោះក្នុងរយៈពេលកំណត់ ១៥ថ្ងៃ។ ចំពោះការសុំចុះបញ្ជីកំណើតរស់ មរណភាព អាពាហ៍ពិពាហ៍ និងការកែតម្រូវកំហុសបច្ចេកទេសដោយមន្ត្រីអត្រានុកូលដ្ឋានមិនតម្រូវឱ្យបង់កម្រៃសេវាទេ។

សរុបជារួមមក ការចុះបញ្ជីអត្រានុកូលដ្ឋានពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រទេសជាតិ និងប្រជាពលរដ្ឋគ្រប់រូប ហើយក៏ជាកត្តាដ៏សំខាន់មួយចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ រួមចំណែកធានានូវការអនុវត្តច្បាប់ និងផែនការអភិវឌ្ឍប្រទេសជាតិ ងាយស្រួលក្នុងការគ្រប់គ្រងស្ថិតិប្រជាជន ការរៀបចំគម្រោងអភិវឌ្ឍន៍ប្រទេសជាតិចំគោលដៅព្រមទាំងទទួលបានប្រសិទ្ធិភាពខ្ពស់ផងដែរ។

# អនុសាសន៍

# អនុសាសន៍

យោងទៅតាមស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ននេះ ខ្ញុំបាទ និងនាងខ្ញុំសង្កេតឃើញថាការចុះបញ្ជីអត្រានុកូលដ្ឋាននៅកម្ពុជាយើងមានលក្ខណៈល្អប្រសើរឡើង ហើយប្រជាពលរដ្ឋក៏បានយល់ដឹងកាន់តែច្បាស់អំពីសារៈសំខាន់នៃអត្រានុកូលដ្ឋានផងដែរ។ ចំពោះភាពល្អប្រសើរនេះកើតឡើងបាន គឺដោយសារការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល ក្រសួងស្ថាប័នពាក់ព័ន្ធនានា និងមន្ត្រីមានសមត្ថកិច្ចដែលខិតខំបំពេញតួនាទីរបស់ខ្លួន និងការខិតខំផ្សព្វផ្សាយអំពីអត្រានុកូលដ្ឋាន ជាពិសេសច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មជូនទៅដល់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋក៏បានចូលរួមបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការទៅសុំចុះបញ្ជីអត្រានុកូលដ្ឋានបានយ៉ាងល្អផងដែរ។ ទោះបីជាការចុះបញ្ជីអត្រានុកូលដ្ឋានមានលក្ខណៈល្អប្រសើរឡើងក៏ពិតមែន ប៉ុន្តែក៏នៅតែមានចំណុចខ្វះខាត និងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចជា ការមិនទាន់មានបច្ចេកទេសទំនើបដែលអាចរក្សាទិន្នន័យអត្រានុកូលដ្ឋាននៅតាមប្រព័ន្ធឌីជីថលបាននៅឡើយ គឺការចុះបញ្ជីអត្រានុកូលដ្ឋានធ្វើឡើងតែនៅក្នុងសៀវភៅ និងសំបុត្រអត្រានុកូលដ្ឋានតែប៉ុណ្ណោះ ដែលអាចប្រឈមទៅនឹងផលប៉ះពាល់ដែលបណ្តាលមកពីគ្រោះទឹកជំនន់ អគ្គិសភ័យ ឬការសឹករិករិលនៃក្រដាស និងករណីប្រធានសក្តិផ្សេងៗទៀតដែលអាចធ្វើឱ្យបាត់បង់នូវទិន្នន័យដើម។ ម្យ៉ាងទៀតខ្ញុំបាទ និងនាងខ្ញុំសង្កេតឃើញថាប្រជាពលរដ្ឋមួយចំនួនកំពុងតែជួបប្រទះនូវបញ្ហា ខុសទិន្នន័យអត្តសញ្ញាណរបស់ខ្លួននៅក្នុងបញ្ជី និងសំបុត្រអត្រានុកូលដ្ឋានជាមួយឯកសារអត្តសញ្ញាណដទៃទៀត រីឯប្រជាពលរដ្ឋខ្លះទៀតបានចុះបញ្ជីអត្រានុកូលដ្ឋានប្រភេទតែមួយលើសពីមួយដង។ ចំណែកឯនីតិវិធីក្នុងការកែតម្រូវ និងការធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋាននៅមានភាពយឺតយ៉ាវ និងលំបាកស្មុកស្មាញដែលមិនអាចឆ្លើយតបបានទៅនឹងសំណូមពរ និងតម្រូវការរបស់ប្រជាពលរដ្ឋនៅឡើយ។ ដើម្បីដោះស្រាយនូវបញ្ហាខាងលើនេះខ្ញុំបាទ និងនាងខ្ញុំសូមជូនជាមតិយោបល់ និងសំណូមពរមួយចំនួនទៅដល់ក្រសួងស្ថាប័ន និងមន្ត្រីអត្រានុកូលដ្ឋានដូចជា៖

- សូមឱ្យអង្គភាព ឬស្ថាប័នមានសមត្ថកិច្ចគប្បីមានការបណ្តុះបណ្តាលមន្ត្រីអត្រានុកូលដ្ឋានឱ្យមានការយកចិត្តទុកដាក់ខ្ពស់បន្ថែមទៀតក្នុងការពិនិត្យ ផ្ទៀងផ្ទាត់ឱ្យបានច្បាស់លាស់ជៀសវាងការខុសឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត និងការចុះលេខជាន់គ្នា ដែលធ្វើឱ្យបាត់បង់ផលប្រយោជន៍ទៅដល់ប្រជាពលរដ្ឋដែលបានចុះបញ្ជីរួចហើយ។
- ក្នុងករណីមានការសរសេរខុស ឬក៏មានការភ័ន្តច្រលំដោយប្រការណាមួយ សូមមន្ត្រីអត្រានុកូលដ្ឋានមានការទទួលខុសត្រូវខ្ពស់ ដោយយកចិត្តទុកដាក់ក្នុងការកែសម្រួលឡើងវិញឱ្យបានឆាប់រហ័ស និងទាន់ពេលវេលាស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋ។

- ក្រសួងស្ថាប័នមានសមត្ថកិច្ច គួរគប្បីមានការប្រើប្រាស់បច្ចេកទេសឌីជីថលឱ្យស្របតាមសង្គមបច្ចុប្បន្ន ដើម្បីរក្សាទិន្នន័យអត្រានុកូលដ្ឋានជៀសវាងបាត់បង់ ឬខូចខាតដោយសារប្រការណាមួយ។
- ក្រសួងស្ថាប័នមានសមត្ថកិច្ច គប្បីពង្រឹង និងផ្សព្វផ្សាយបន្ថែមទៀតអំពីបច្ចេកទេសឌីជីថលដើម្បីឱ្យប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការស្វែងរកទិន្នន័យ និងអាចចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធឌីជីថលបានផងដែរ។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារយោងជាលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។
- ច្បាប់ ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, ព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣។
- ច្បាប់ ស្តីពីសញ្ជាតិ, ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨, ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨។
- ច្បាប់ ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦។
- ច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ៥៦ ក្រ. ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៩។
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល, លេខ ២៥២ អនក្រ.បក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១។
- អនុក្រឹត្យ ស្តីពីការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រើសារពើពន្ធ, លេខ ៦២ អនក្រ.បក, ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤។
- អនុក្រឹត្យ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ ១៧ អនក្រ.បក, ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤។
- អនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា៨ និងមាត្រា៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន, លេខ ៦០ អនក្រ.បក, ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២។
- អនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០។
- សេចក្តីណែនាំ ស្តីពីការបន្តដំណើរការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន, លេខ ០៤៥ សណន, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩។
- សេចក្តីណែនាំ ស្តីពីការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន, លេខ ០៣៥ សណន, ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧។
- សេចក្តីណែនាំអន្តរក្រសួង ស្តីពីការកែតម្រូវ និងបំពេញចំណុចខ្វះខាតនៅក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ, លេខ ០១០ ស.ណ.ន.ម.ផ.កយ/០៧, ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧។

- សេចក្ដីណែនាំ ស្ដីពីការចុះសៀវភៅអត្រានុកូលដ្ឋានឱ្យមាននិរន្តរភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត, លេខ ០០៨, ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧។

## ២. ឯកសារយោងជាសៀវភៅតែងនិពន្ធ

- កម្រងឯកសារ ស្ដីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន។
- សៀវភៅលោកនីតិ,លី ធាមតេង, បោះពុម្ពឆ្នាំ១៩៦៧។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១៖** ច្បាប់ ស្តីពីអគ្រានុកូលដ្ឋាន ស្ថិតិអគ្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

**ឧបសម្ព័ន្ធទី២៖** អនុក្រឹត្យ ស្តីពីអគ្រានុកូលដ្ឋាន។

**ឧបសម្ព័ន្ធទី៣៖** អនុក្រឹត្យ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋាន។

## ២. ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១៖** គំរូលិខិតនានានៃអគ្រានុកូលដ្ឋានកំណើត។

**ឧបសម្ព័ន្ធទី២៖** គំរូលិខិតនានានៃអគ្រានុកូលដ្ឋានអាពាហ៍ពិពាហ៍។

**ឧបសម្ព័ន្ធទី៣៖** គំរូលិខិតនានានៃអគ្រានុកូលដ្ឋានមរណភាព។

**ឧបសម្ព័ន្ធទី៤៖** រូបភាពក្នុងពិធីបើកវគ្គបណ្តុះបណ្តាលតម្រង់ទិសគ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្តសម្រាប់ការផ្សព្វផ្សាយច្បាប់ ស្តីពីអគ្រានុកូលដ្ឋាន ស្ថិតិអគ្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

**ឧបសម្ព័ន្ធទី៥៖** រូបភាពនៃសិក្ខាសាលាអំពីការផ្សព្វផ្សាយ ច្បាប់ស្តីពីអគ្រានុកូលដ្ឋាន ស្ថិតិអគ្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។